01220718

**Declassified to Public**
**27 June 2019**

E346/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

**ចំពោះមុខ:** ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម **Jean-Marc LAVERGNE**
ចៅក្រម **យ៉ា សុខន**
ចៅក្រម **Claudia FENZ**
ចៅក្រម **យូរ ឧត្តរា**

**កាលបរិច្ឆេទ:** ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦
**ភាសាដើម:** ខ្មែរ/អង់គ្លេស/បារាំង
**ចំណាត់ថ្នាក់ឯកសារ:** សម្ងាត់

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 31 / 03 / 2016
ម៉ោង (Time/Heure): 13 : 30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

---

**សំអាងហេតុសម្រាប់សេចក្តីសម្រេចលើសំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំស្តាប់សាក្សីបន្ថែមសម្រាប់សវនាការជំនុំជម្រះនៃសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ និងសេចក្តីសម្រេចលើសាក្សីឈ្មោះ សាន់ ឡុន (2-TCW-1007), ស៊ូ តិរិទ្ធ (2-TCW-1027) និង អ៊ុច សារី (2-TCW-1026)**

**(ឯកសារ E346/2)**

---

**<u>សហព្រះរាជអាជ្ញា</u>**
ជា លាង
Nicholas KOUMJIAN

**<u>ជនជាប់ចោទ</u>**
នួន ជា
ខៀវ សំផន

01220719

002/19-09-2007-អវតក/អជសដ

E346/3


**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Marie GIRAUD

**មេធាវីជនជាប់ចោទ**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ

## ១. សេចក្ដីផ្ដើម

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើរួមរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំស្ដាប់សក្ខីកម្មសាក្សីបន្ថែមចំនួន ១៥ រូប ពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់[1]។ សំណើនេះបែងចែកសាក្សីទាំង ១៥ រូបជា ៦ ប្រភេទ៖ ១) សាក្សីមួយរូបស្ដីពីការប្រព្រឹត្តចំពោះអតីតទាហាន និងអ្នករដ្ឋការរបប លន់ នល់ ២) អតីតអ្នកទោស ៥ រូបនៅក្រាំងតាចាន់ ៣) អតីតបុគ្គលិក ៣ រូបនៅក្រាំងតាចាន់ ៤) អតីតកម្មាភិបាល ២ រូបនៅត្រាំកក់ ៥) សាក្សី ២ រូបស្ដីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និង ៦) សាក្សី ២ រូបស្ដីពីយថាភាពនៃឯកសារ។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") បានដាក់ចម្លើយតបរបស់ខ្លួននៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៥ ហើយសហព្រះរាជអាជ្ញា និងមេធាវីការពារក្ដី ខៀវ សំផន បានឆ្លើយតបផ្ទាល់មាត់ក្នុងអំឡុងពេលសវនាការថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥[2]។

២. នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៥ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយ និងចេញសំអាងហេតុនៅពេលបន្ទាប់ ដោយទទួលយកសំណើទាក់ទងនឹងសាក្សីពីររូប៖ មួយរូបស្ដីពីការប្រព្រឹត្តចំពោះអតីតអ្នករដ្ឋការរបប លន់ នល់ ឈ្មោះ សៅ វ៉ន (2-TCW-989) និងអតីតអ្នកទោសមួយរូបក្នុងចំណោមអ្នកទោសនានានៅក្រាំងតាចាន់ ឈ្មោះ វង្ស សារុន (2-TCW-986)[3]។ អង្គជំនុំជម្រះបានពន្យារពេលចេញសេចក្ដីសម្រេចរបស់ខ្លួនទៅលើបុគ្គលប្រាំរូប ក្នុងចំណោមបុគ្គលទាំងអស់ដែលស្នើឡើង រួមទាំង ឈ្មោះ សាន់ ឡុន (2-TCW-1007) និងបានបដិសេធបុគ្គល

---

[1] សំណើរួមរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំស្ដាប់សាក្សីបន្ថែម សម្រាប់សវនាការផ្នែកទីមួយនៃសំណុំរឿង ០០២/០២ អំពីសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ ឯកសារ E346 ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ("សំណើ")។

[2] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ទៅនឹងសំណើរួមរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំស្ដាប់សាក្សីបន្ថែម សម្រាប់សវនាការផ្នែកទីមួយនៃសំណុំរឿង ០០២/០២ អំពីសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ ឯកសារ E346/1 ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៥ ("ចម្លើយតបរបស់សហមេធាវីនាំមុខ")។ ប្រតិចារឹកសវនាការ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥ ទំព័រ ៦៥ ដល់ ៦៧។

[3] សេចក្ដីសម្រេចលើសំណើរួមរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំស្ដាប់សាក្សីបន្ថែមសម្រាប់សវនាការវគ្គដំបូងនៃសំណុំរឿង ០០២/០២ អំពីសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ ឯកសារ E346/2 ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៥ ("សេចក្ដីសម្រេចលើសំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង")។

ប្រាំពីររូបផ្សេងទៀតដែលមាននៅក្នុងសំណើ[4]។ ទាក់ទងនឹងឈ្មោះ សាន់ ឡួន (2-TCW-1007) នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះសម្រេចស្ដាប់សក្ខីកម្មបុគ្គលរូបនេះ ក្នុងអំឡុងពេលវគ្គសវនាការស្ដីពីការប្រព្រឹត្តិចំពោះក្រុមគោលដៅជាក់លាក់[5]។ តទៅនេះ អង្គជំនុំជម្រះផ្ដល់សំអាងហេតុសម្រាប់សេចក្ដីសម្រេចរបស់ខ្លួន និងសម្រេចទៅលើសំណើសុំកោះហៅសាក្សីពីររូបក្នុងចំណោមសាក្សីដែលបានស្នើឡើង ដែលអង្គជំនុំជម្រះបានពន្យារពេលចេញសេចក្ដីសម្រេច រួមមាន ឈ្មោះ ស៊ូ ភីរិន្ទ (2-TCW-1027) និង អ៊ុំ សារិ (2-TCW-1026)។

## ២. សារណា

### ២.១ មេធាវីការពារក្ដី នួន ជា

#### ២.១.១ *ការប្រព្រឹត្តិចំពោះអតីតទាហាន និងអ្នករដ្ឋការរបប លន់ នល់*

៣. មេធាវីការពារក្ដី នួន ជា លើកឡើងថា សាក្សីដែលបានស្នើឡើងឈ្មោះ សៅ វ៉ន (2-TCW-989) អាចផ្ដល់ "ភស្ដុតាងដោះបន្ទុកពិសេស ហើយសំខាន់" ទាក់ទងនឹងការប្រព្រឹត្តិចំពោះអតីតទាហាន និងអ្នករដ្ឋការរបប លន់ នល់ នៅសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់[6]។ មេធាវីការពារក្ដីលើកឡើងថា ចម្លើយរបស់ សៅ វ៉ន មិនអាចរកបាន នៅមុនពេលចាប់ផ្ដើមដំណើរការ

---

[4] សេចក្ដីសម្រេចលើសំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ទំព័រ ២។

[5] សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ផ្ញើជូនភាគីទាំងអស់ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥។

[6] សំណើ កថាខណ្ឌ ៧។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា ក្រោយមក សៅ វ៉ន (2-TCW-989) បានផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល នៅក្នុងបរិបទនៃបណ្ដឹងសាទុក្ខប្រឆាំងនឹងសំណុំរឿង ០០២/០១ នៅថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០១៥ សូមមើលឯកសារ F1/1.1។ នៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៦ មេធាវីការពារក្ដី នួន ជា បានសុំដក សៅ វ៉ន (2-TCW-989) ចេញពីបញ្ជីសាក្សីដែលបានស្នើសម្រាប់សំណុំរឿង ០០២/០២។ សំណើនេះត្រូវបានអង្គជំនុំជម្រះសាលាដំបូងបដិសេធនៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ ហើយ សៅ វ៉ន បានផ្ដល់សក្ខីកម្មនៅចំពោះមុខ អង្គជំនុំជម្រះ នៅថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១៦។ សូមមើល សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដី នួន ជា សុំដកសាក្សីមួយចេញពីបញ្ជីសាក្សីសម្រាប់សវនាការ នៅក្នុងសំណុំរឿង ០០២/០២ (ឯកសារ E364/2/1) ឯកសារ E346/2/2 ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦។ សំណើរបស់ នួន ជា សុំដកសាក្សីចេញពីបញ្ជីសាក្សីសម្រាប់សវនាការនៅក្នុងសំណុំរឿង ០០២/០២ ឯកសារ E346/2/1 ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៦។ ប្រតិចារឹកសវនាការ ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១៦ (សៅ វ៉ន)។

ជំនុំជម្រះក្នុងខែ មិថុនា ឆ្នាំ ២០១១ ទេ ដោយសារចម្លើយនេះត្រូវបានដាក់បង្ហាញដល់មេធាវីការពារក្តីត្រឹមថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៣។ មេធាវីការពារក្តី នួន ជា លើកឡើងថា ដោយសារចម្លើយនេះត្រូវបានដាក់បង្ហាញចំពេលដែលមានការមមាញឹក ជាពិសេសនោះ មេធាវីការពារក្តីទើបតែបានដឹងពីចម្លើយនេះ នៅពេលខ្លួនរៀបចំបញ្ចប់សារណាលើបណ្តឹងសាទុក្ខសម្រាប់សំណុំរឿង ០០២/០១ ប៉ុណ្ណោះ។ ទាក់ទងនឹងចំណុចនេះ និងដោយកត់សម្គាល់នូវភស្តុតាងផ្សេងទៀតដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងប្រធានបទនេះ មេធាវីការពារក្តី នួន ជា លើកឡើងថា វាជាប្រយោជន៍យុត្តិធម៌ដែលត្រូវទទួលយកសំណើរបស់ខ្លួននាពេលនេះ[7]។

### ២.១.២ *អតីតអ្នកទោសនៅក្រាំងតាចាន់*

៤. មេធាវីការពារក្តី នួន ជា ស្នើសុំកោះហៅសាក្សីបន្ថែមដែលជាអតីតអ្នកទោសប្រាំរូបនៅក្រាំងតាចាន់ ("អតីតអ្នកទោស") រួមមាន៖ មាស សារ៉ាត់ (2-TCW-821) និង ហ៊ិន គឹមសេង (2-TCW-1018)[8] អ៊ួច ហាន (2-TCW-1019) និង វង្ស សារុន (2-TCW-986)[9] និង សែត យែម (2-TCCP-1020)[10]។ មេធាវីការពារក្តីលើកឡើងថា សក្ខីកម្មដែលបានស្តាប់ និងភស្តុតាងដែលបានបង្ហាញអំពីក្រាំងតាចាន់បានដើរតួនាទីយ៉ាងធំក្នុងការ "បង្កើនភាពផ្ទុយគ្នា និងភាពមិនច្បាស់លាស់នៃភស្តុតាងដែលមានស្រាប់"[11]។ មេធាវីការពារក្តី នួន ជា អះអាងថា សក្ខីកម្មរបស់អតីតអ្នកទោស "ពិតប្រាកដ" ទាំងប្រាំរូបនេះ អាចជួយដល់ការស្វែងរកការពិត ហើយប្រាកដជាផ្តល់ផលប្រយោជន៍យុត្តិធម៌ និងទាក់ទងយ៉ាងខ្លាំងទៅនឹងភស្តុតាងដែលបានបង្ហាញរួចហើយ[12]។

---

[7] សំណើ កថាខណ្ឌ ៧ ដល់ ៨។

[8] អ្នកទាំងពីរគឺជាបងប្អូនស្រី និងជាម្តាយរបស់ មាស សុខា ដែលបានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី ៨ និងទី ២១ ដល់ ២២ ខែ មករា ឆ្នាំ ២០១៥។ *សូមមើល* សំណើ កថាខណ្ឌ ១១។

[9] សំណើ កថាខណ្ឌ ១៣ ដល់ ១៤។

[10] សំណើ កថាខណ្ឌ ១៥ ដល់ ១៦។

[11] សំណើ កថាខណ្ឌ ១០។

[12] សំណើ កថាខណ្ឌ ១០។

៥. មេធាវីការពារក្ដី នួន ជា លើកឡើងថា ទាក់ទងនឹងស្ថានភាពនៃភស្តុតាងដែលពាក់ព័ន្ធនឹងក្រាំងតាចាន់ នាពេលនេះ ភស្តុតាងរបស់ មាស សារ៉ាត់ (2-TCW-821) និង ហ៊ុន គីមសេង (2-TCW-1018) មានសារៈសំខាន់ក្នុងការបញ្ជាក់បំភ្លឺពីលក្ខណៈនៃការសួរចម្លើយ ការងារទទួលខុសត្រូវរបស់អ្នកទោស ការឃុំខ្លួន និងការសម្លាប់ប្ដីរបស់ពួកគាត់ដែលរងការចោទប្រកាន់ ព្រមទាំង "ស្ថានភាព ប្រតិបត្តិការ បុគ្គលិក និងអ្នកទោសជាទូទៅ"[13]។ ជាពិសេស ទាក់ទងនឹង មាស សារ៉ាត់ (2-TCW-821) មេធាវីការពារក្ដី នួន ជា លើកឡើងថា គាត់ជាបុគ្គលដែលគេបានផ្ដោតសំខាន់ក្នុងសក្ខីកម្មនៃសវនាការផ្នែកនេះ ដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍នៃការរំលោភផ្លូវភេទដែលបានកំណត់នៅក្នុងដីកាដំណោះស្រាយ[14]។ ដោយពិចារណាពីភាពធ្ងន់ធ្ងរនៃការចោទប្រកាន់ ភស្តុតាងមានភាពចម្រុះលើករណីនេះ ដែលថា ការរំលោភផ្លូវភេទដែលត្រូវបានចោទប្រកាន់ មិនត្រូវបានលើកឡើងដោយ មាស សុខា (2-TCW-936) ឬ ហ៊ុន គីមសេង (2-TCW-1018) នោះ មេធាវីការពារក្ដី នួន ជា លើកជាទឡ្ហីករណ៍ថា នាពេលនេះ ការកោះហៅសាក្សីរូបនេះគឺជាការចាំបាច់។ មេធាវីការពារក្ដី នួន ជា លើកឡើងថា ខ្លួនមិនបានដឹងពី មាស សារ៉ាត់ (2-TCW-821) នៅពេលចាប់ផ្ដើមសវនាការ ហើយថា ទោះបីខ្លួនបានដឹងពី ហ៊ុន គីមសេង (2-TCW-1018) ក៏ដោយ ក៏ខ្លួនមិនបានយល់ថា សក្ខីកម្មរបស់គាត់មានភាពចាំបាច់នោះទេរហូតដល់ពេលនេះ[15]។

៦. មេធាវីការពារក្ដី នួន ជា លើកឡើងថា អ៊ុច ហាន (2-TCW-1019) និង វង្ស សារុន (2-TCW-986) ជាបុគ្គលិកពេទ្យស្រីពីររូបដែលត្រូវបានឃុំខ្លួននៅក្រាំងតាចាន់ អាចផ្ដល់សក្ខីកម្មអំពីស្ថានភាពមន្ទីរពេទ្យនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅថ្នាក់ស្រុក និងភូមិភាគ រួមទាំង ស្ថានភាព ប្រតិបត្តិការ បុគ្គលិក និងអ្នកទោសនៅក្រាំងតាចាន់បាន។ ក្រៅពីនេះ មេធាវីការពារក្ដីលើកឡើងថា វង្ស សារុន (2-TCW-986) អាចផ្ដល់ព័ត៌មានពីមេគុកក្រាំងតាចាន់ឈ្មោះ តា អាន ដោយសារគាត់ជា "ស្រី" របស់មេគុកនោះ[16]។ មេធាវីការពារក្ដី នួន ជា លើកឡើងបន្ថែមថា សាក្សីទាំងពីររូបនេះមិនត្រូវបានស្ដាប់ចម្លើយពីសំណាក់ ក.ស.ច.ស ទេ ហើយថា ទោះបីឈ្មោះពួកគេមាននៅ

---

[13] សំណើ កថាខណ្ឌ ១១។

[14] សំណើ កថាខណ្ឌ ១១ ដល់ ១២។ ដីកាដំណោះស្រាយ កថាខណ្ឌ ៥០៥។

[15] សំណើ កថាខណ្ឌ ១១ ដល់ ១២។

[16] សំណើ កថាខណ្ឌ ១៣ ដល់ ១៤។

ក្នុងកំណត់ហេតុនៅក្រាំងតាចាន់ក៏ដោយ ក៏មេធាវីការពារក្តីមិនបានកំណត់អត្តសញ្ញាណពួកគេជាសាក្សីសក្តានុពលដែរ។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីទាំងពីររូបត្រូវបានកំណត់អត្តសញ្ញាណ និងបានពិភាក្សានៅក្នុងតុលាការ ក្នុងនាមជាអតីតអ្នកទោសដែលនៅរស់រានមានជីវិត។ ហេតុនេះ នាពេលនេះ មេធាវីការពារក្តីយល់ថា សក្ខីកម្មរបស់ពួកគេមានសារៈសំខាន់[17]។

៧. ទាក់ទងនឹង សែត ឃែម (2-TCCP-1020) ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤ មេធាវីការពារក្តី នួន ជា លើកឡើងថា សក្ខីកម្មរបស់គាត់មានសារៈសំខាន់ ដោយសារគាត់អាចផ្តល់ពន្លឺអំពីបញ្ហាសំខាន់មួយដែល "មិនត្រូវបានលើកឡើងនៅក្នុងដីកាដំណោះស្រាយទាល់តែសោះ ដែលថា អ្នកជាប់ឃុំនៅក្រាំងតាចាន់អាចត្រូវបានដោះលែងចេញពីមន្ទីរសន្តិសុខ ហើយត្រឡប់មករស់នៅក្នុងសហករណ៍វិញ"[18]។ ក្រៅពីនេះ ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានស្នើរូបនេះអាចផ្តល់ការបំភ្លឺ ទាក់ទងនឹងបញ្ហានានាដែលមានភ័ស្តុតាងផ្ទុយគ្នា រួមទាំងបញ្ហាថាតើ ការរំលោភផ្លូវភេទ ឬការបំពារបំពានផ្លូវភេទ ត្រូវបានកើតឡើងនៅមន្ទីរសន្តិសុខ ឬយ៉ាងណា ស្ថានភាព ប្រតិបត្តិការ កម្មាភិបាល និងអ្នកទោសនៅក្រាំងតាចាន់ ពីវិធីសាស្ត្រនៃការសម្លាប់ដែលរងការចោទប្រកាន់ ចំនួនអ្នកទោសដែលត្រូវបានបញ្ជូនទៅទីនោះក្នុងមួយថ្ងៃ ព្រមទាំងបញ្ហាថាតើអ្នកជាប់ឃុំ រួមមាន ខ្មែរក្រោម ជនជាតិចាម និងជនជាតិវៀតណាម ដែរ ឬទេ[19]។ មេធាវីការពារក្តី នួន ជា លើកឡើងថា ខ្លួនបានទទួលចម្លើយរបស់គាត់នៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ដែលហេតុនេះ មេធាវីការពារក្តីមិនអាចរកបាន សក្ខីកម្មរបស់គាត់ នៅមុនពេលដំណើរការជំនុំជម្រះក្តី ក្នុងឆ្នាំ ២០១១ ទេ[20]។

### ២.១.៣ *អតីតបុគ្គលិកនៅក្រាំងតាចាន់*

---

[17] សំណើ កថាខណ្ឌ ១៣។

[18] សំណើ កថាខណ្ឌ ១៦។

[19] សំណើ កថាខណ្ឌ ១៦។

[20] សំណើ កថាខណ្ឌ ១៥។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយ [កោសលុប] សម្ងាត់បំផុត ឯកសារ E319/12.3.6 ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១៤។ ការដាក់បង្ហាញសម្ភារៈសម្ងាត់នៅក្នុងសំណុំរឿង ឯកសារ E319/12/1.2 ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥។

៨. មេធាវីការពារក្តី នួន ជា លើកឡើងថា សក្ខីកម្មរបស់ សាំង ស៊ឹម (2-TCW-1021), តួច (2-TCW-1022) និង អ៊ួក (2-TCW-1023) ដែលអ្នកទាំងអស់គ្នាជាអតីតបុគ្គលិកនៅក្រាំងតាចាន់ អាចជួយដល់អង្គជំនុំជម្រះក្នុងការស្វែងរកការពិត រួមទាំង ស្ថានភាព ប្រតិបត្តិការ ការសម្លាប់ និង ការរំលោភផ្លូវភេទ/ការបំពារបំពានផ្លូវភេទ នៅមន្ទីរសន្តិសុខនោះ[21]។ មេធាវីការពារក្តីលើកឡើងថា ទោះបីពួកគេបានដឹងពី សាំង ស៊ឹម (2-TCW-1021) ក៏ដោយ ក៏ពួកគេមិនបានដឹងពីមនុស្សពីរនាក់ទៀតដែល ក.ស.ច.ស មិនបានស្តាប់ចម្លើយ តែត្រូវបានលើកឡើងនៅក្នុងចម្លើយរបស់សាក្សីមួយចំនួននោះទេ។ នៅក្នុងកាលៈទេសៈណាក៏ដោយ មេធាវីការពារក្តី នួន ជា លើកជាទឡ្ហីករណ៍ថា ខ្លួនមិនបានយល់ថា សក្ខីកម្មរបស់ពួកគាត់មានភាពចាំបាច់នោះទេ រហូតមកទល់ពេលនេះ[22]។

**២.១.៤ *អតីតកម្មាភិបាលស្រុកត្រាំកក់***

៩. មេធាវីការពារក្តី នួន ជា ស្នើសុំកោះហៅអតីតកម្មាភិបាលស្រុកត្រាំកក់ពីររូបឈ្មោះ សាន់ ឡួន (2-TCW-1007) និង ទឹម ហ៊ី (2-TCW-833) ដើម្បីជួយដល់អង្គជំនុំជម្រះក្នុងការស្វែងរកការពិតពាក់ព័ន្ធនឹងប្រតិបត្តិការសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ ទំនាក់ទំនងទៅវិញទៅមករវាងទីតាំងទាំងនេះ និងរបៀបដែលទីតាំងទាំងនេះស្ថិតនៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ស្រុកត្រាំកក់ តាមឃុំនានានៅក្នុងស្រុកនោះ រួមទាំងតំបន់ និងភូមិភាគដែលគ្រប់គ្រងស្រុកនោះ។ មេធាវីការពារក្តី នួន ជា លើកឡើងថា ចម្លើយរបស់សាក្សីទាំងពីររូបនេះជាផ្នែកនៃការដាក់បង្ហាញពីសំណុំរឿង ០០៤ ដែលខ្លួនទទួលបាន ចាប់តាំងពីពេលចាប់ផ្តើមដំណើរការសំណុំរឿង ០០២/០២[23]។

១០. មេធាវីការពារក្តី នួន ជា លើកឡើងថា សាន់ ឡួន (2-TCW-1007) ធ្លាប់ធ្វើជានីរសាស្រុក ហើយថា គាត់អាចផ្តល់ព័ត៌មានស៊ីជម្រៅពីការនាំបញ្ជា និងការដឹកជញ្ជូនមនុស្សនៅក្នុងស្រុកនោះ។ មេធាវីការពារក្តីក៏លើកឡើងផងដែរថា គាត់អាចផ្តល់សក្ខីកម្មស្តីពីថ្នាក់ដឹកនាំក្នុងតំបន់នោះដែរ រួមមាន តួនាទីរបស់ ពេជ្រ ជឹម (2-TCW-809), ភី និង ខឹម បឿន (2-TCW-979) ស្តីពី "ខ្មាំងផ្ទៃក្នុង

[21] សំណើ កថាខណ្ឌ ១៧។

[22] សំណើ កថាខណ្ឌ ១៧។

[23] សំណើ កថាខណ្ឌ ១៨ ដល់ ២០។

នៅក្នុង ប.ក.ក” និងស្តីពីគោលនយោបាយផ្នែកកសិកម្ម។ មេធាវីការពារក្តី នួន ជា លើកឡើងថា ខ្លួនបានទទួលចម្លើយរបស់គាត់នៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៥[24]។

១១. មេធាវីការពារក្តី នួន ជា លើកឡើងថា ក្នុងនាមជានីរសាស្រុកម្នាក់ដែលទទួលខុសត្រូវនាំសំបុត្រពីប្រធានស្រុក ជីម និង គិត ទៅឱ្យ អាន នៅក្រាំងតាចាន់, ទឹម ហ៊ី (2-TCW-933) អាចផ្តល់ព័ត៌មានស៊ីជម្រៅអំពីតួនាទីរបស់ ជីម, គិត និង អាន។ មេធាវីការពារក្តីក៏លើកឡើងផងដែរថា សាក្សីដែលស្នើឡើងរូបនេះអាចផ្តល់ព័ត៌មានពិស្តារបន្ថែមទៀតអំពីស្ថានភាព ប្រតិបត្តិការ បុគ្គលិក និងអ្នកទោសនៅក្រាំងតាចាន់។ ក្រៅពីនេះ ក្នុងនាមជានីរសាររបស់ វ៉ន វេត, ទឹម ហ៊ី (2-TCW-933) ក៏អាចផ្តល់ព័ត៌មានស៊ីជម្រៅអំពីមេដឹកនាំជាន់ខ្ពស់ក្នុង ប.ក.ក ដែរ។ មេធាវីការពារក្តី នួន ជា លើកឡើងថា ខ្លួនបានទទួលចម្លើយរបស់គាត់នៅថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤[25]។

### ២.១.៥ *សាក្សីស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ*

១២. មេធាវីការពារក្តី នួន ជា ក៏ស្នើសុំស្តាប់សក្ខីកម្មសាក្សីពីររូបបន្ថែមទៀតស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឈ្មោះ ទ្រី ទូច (2-TCW-1024) និង សេង អុល (2-TCW-1025)។ មេធាវីការពារក្តីលើកឡើងថា សហករណ៍ត្រាំកក់ត្រូវបានកំណត់អត្តសញ្ញាណជាទីតាំងឧក្រិដ្ឋកម្មសំខាន់មួយក្នុងចំណោមទីតាំងឧក្រិដ្ឋកម្មសំខាន់ៗសម្រាប់ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[26]។ ទាក់ទងនឹងលក្ខណៈ “ចម្រុះ” នៃសក្ខីកម្មសាក្សីដែលបានស្តាប់ដោយផ្ទាល់កន្លងមក និងទាក់ទងនឹងការយកចិត្តទុកដាក់ដល់ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ ជាំង ស្រីមុំ (2-TCW-834) ដែលរងការចោទប្រកាន់នោះ មេធាវីការពារក្តី នួន ជា លើកឡើងថា ការកោះហៅសាក្សីទាំងពីររូបនេះ គឺមាន

---

[24] សំណើ កថាខណ្ឌ ១៩។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយ [កោសលុប] សម្ងាត់បំផុត ឯកសារ E319/13.3.60 ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។ ការដាក់បង្ហាញសម្ភារៈសម្ងាត់នៅក្នុងសំណុំរឿង ឯកសារ E319/13/1.3។

[25] សំណើ កថាខណ្ឌ ២០។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយ [កោសលុប] សម្ងាត់បំផុត ឯកសារ E319.1.29។ ការដាក់បង្ហាញសម្ភារៈសម្ងាត់នៅក្នុងសំណុំរឿង ឯកសារ E319/4.1។

[26] សំណើ កថាខណ្ឌ ២១ ដល់ ២៤។

សារៈសំខាន់ ដោយសារតែពួកគាត់ជាប់ទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលត្រូវបានចោទប្រកាន់[27]។

១៣. សេង អុល (2-TCW-1025) ជាប្រធានកងនារី ដែលបានធ្វើជាអធិបតីនៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍របស់ ជាំង ស្រីមុំ ដែលត្រូវបានគេចោទថាជាការបង្ខំ និងដែល ជាំង ស្រីមុំ បានកំណត់អត្តសញ្ញាណថា ជាមនុស្សដែលគាត់មិនហ៊ានប្រកែក។ មេធាវីការពារក្តី នួន ជា លើកឡើងថា សេង អុល (2-TCW-1025) អាចផ្តល់ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលត្រូវបានចោទប្រកាន់ ពីទស្សនៈ និងព័ត៌មានស៊ីជម្រៅក្នុងនាមជាកម្មាភិបាលមួយរូប ពាក់ព័ន្ធនឹងគោលនយោបាយនៃការដាក់បទបញ្ជាទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍។ មេធាវីការពារក្តី នួន ជា លើកឡើងបន្ថែមទៀតថា ទោះបីមេធាវីការពារក្តីទទួលបានចម្លើយរបស់ សេង អុល (2-TCW-1025) មុនពេលចាប់ផ្តើមសវនាការនៅឆ្នាំ ២០១១ ក៏ដោយ ក៏សក្ខីកម្មរបស់គាត់មិនទាន់មានសារៈសំខាន់នោះទេ រហូតមកទល់ពេលនេះ[28]។

១៤. មេធាវីការពារក្តី នួន ជា លើកឡើងថា ក្នុងនាមជាប្តីរបស់ ជាំង ស្រីមុំ (2-TCW-834), ទ្រី ទូច (2-TCW-1024) នឹងអាចផ្តល់សក្ខីកម្មស្តីពីកាលៈទេសៈនានានៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលត្រូវបានចោទប្រកាន់។ ជាងនេះទៀត គាត់អាចផ្តល់យោបល់សំខាន់ក្នុងនាមជាប្តីម្នាក់ ចំពោះសញ្ញាណនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ មេធាវីការពារក្តី នួន ជា លើកឡើងថា ទោះបីជាលក្ខណៈបច្ចេកទេស សាក្សីរូបនេះត្រូវគេស្គាល់ ដោយសារគាត់មានឈ្មោះនៅក្នុងចម្លើយរបស់ ជាំង ស្រីមុំ ក៏ដោយ ក៏សក្ខីកម្មរបស់គាត់ទើបតែមានសារៈសំខាន់ ពាក់ព័ន្ធនឹងសក្ខីកម្មរបស់ ជាំង ស្រីមុំ នៅពេលនេះតែប៉ុណ្ណោះ[29]។

**២.១.៦ *យថាភាពនៃឯកសារ***

---

27 សំណើ កថាខណ្ឌ ២២ ដល់ ២៤។ ជាំង ស្រីមុំ (2-TCW-834) បានផ្តល់សក្ខីកម្មនៅថ្ងៃទី ២៩ ខែ មករា និង ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១៥។

28 សំណើ កថាខណ្ឌ ២៣។

29 សំណើ កថាខណ្ឌ ២៤។

១៥. ជាចុងក្រោយ មេធាវីការពារក្តី នួន ជា ស្នើសុំកោះហៅសាក្សីពីររូបបន្ថែម គឺឈ្មោះ អ៊ីវ សារិ (2-TCW-1026) និង ស៊ូ ភីរិន្ទ (2-TCW-1027) ឱ្យមកផ្តល់សក្ខីកម្ម ពាក់ព័ន្ធនឹងទីតាំងនៃសំណៅដើមរបស់ឯកសារចំនួន ១៣៥ នៅក្នុងសំណុំរឿង ដែលទាក់ទងនឹងកំណត់ហេតុនានាពីត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ និងនៅថ្នាក់លើ និងថ្នាក់ក្រោម។ មានការអះអាងថា អ៊ីវ សារិ (2-TCW-1026) ធ្លាប់ធ្វើជាអនុប្រធានមន្ទីរអប់រំខេត្តតាកែវមួយរយៈ[30] ចំណែក ស៊ូ ភីរិន្ទ (2-TCW-1027) ធ្លាប់ធ្វើជាអភិបាលខេត្តតាកែវក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ បន្ទាប់មកជាអភិបាលខេត្តសៀមរាប។ បច្ចុប្បន្ន គាត់មានតំណែងជារដ្ឋលេខាធិការនៅទីស្តីការគណៈរដ្ឋមន្ត្រី[31]។ មេធាវីការពារក្តី នួន ជា កត់សម្គាល់ថា មានព័ត៌មានបង្ហាញថា អ៊ីវ សារិ (2-TCW-1026) បានផ្តល់សំណៅដើមទៅឱ្យ Ben Kiernan ក្នុងនាម ស៊ូ ភីរិន្ទ (2-TCW-1027) ហើយថា Ben Kiernan មិនបានប្រគល់សំណៅដើមត្រឡប់មកវិញទេ[32]។ មេធាវីការពារក្តី នួន ជា លើកឡើងថា ទោះបីខ្លួនអាចស្នើសុំកោះហៅបុគ្គលទាំងនេះឱ្យមកផ្តល់សក្ខីកម្មនៅពេលចាប់ផ្តើមសវនាការក៏ដោយ ក៏មេធាវីការពារក្តីមិនទាន់ចាត់ទុកថា សក្ខីកម្មរបស់ពួកគេមានសារៈសំខាន់ទេនៅពេលមុនៗ។ ក៏ប៉ុន្តែដោយសារមានការលើកឯកសារទាំងនេះមកសំអាងជាញឹកញាប់នោះ នាពេលនេះ វាជាការចាំបាច់ដែលត្រូវកោះហៅសាក្សីទាំងពីររូបនេះឱ្យមកផ្តល់សក្ខីកម្ម ដោយសារពួកគេអាចផ្តល់ព័ត៌មានស៊ីជម្រៅបន្ថែមទៀតពីទីកន្លែងដែលឯកសារដើមទាំងអស់ត្រូវបានរកឃើញ ប្រភព ដំណើរការគ្រប់គ្រងឯកសារ យថាភាព និងភាពជឿជាក់បាន[33]។

## ២.២ សារណាតបរបស់សហព្រះរាជអាជ្ញា

១៦. សហព្រះរាជអាជ្ញាឆ្លើយតបថា ផ្ទុយពីការលើកឡើងរបស់មេធាវីការពារក្តី នួន ជា ដែលថាភស្តុតាងមានភាពច្របូកច្របល់នេះ មានភស្តុតាងស្របគ្នាទាំងពីរកម្មាភិបាល និងជនរងគ្រោះទៅលើចំណុចសំខាន់ៗ៖ មនុស្សស្ទើរតែទាំងអស់ដែលត្រូវបានឃុំខ្លួននៅក្រាំងតាចាន់ត្រូវបានសម្លាប់

---

30 សំណើ កថាខណ្ឌ ២៥, ២៧ ដល់ ២៨។

31 សំណើ កថាខណ្ឌ ២៧។

32 សំណើ កថាខណ្ឌ ២៧ ដល់ ២៨។

33 សំណើ កថាខណ្ឌ ២៦ ដល់ ២៨។

និងមិនត្រូវបានដោះលែងទេ ក្មេងៗមិនត្រូវបានទុកជីវិត ហើយប្រជាជនត្រូវបានទទួលរងការធ្វើទារុណកម្ម ធ្វើឱ្យថប់ដង្ហើម និងវាយដំដើម្បីឱ្យឆ្លើយសារភាព[34]។

១៧. សហព្រះរាជអាជ្ញាឆ្លើយតបថា សាក្សី សៅ វ៉ន (2-TCW-989) និង សេង អុល (2-TCW-1025) ហាក់ដូចជាមានព័ត៌មានដោះបន្ទុកសក្ដានុពល ហើយថា ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងគួរស្ដាប់សក្ខីកម្មពួកគេ ទាក់ទងនឹងការប្រព្រឹត្តិចំពោះអតីតទាហាន និងអ្នករដ្ឋការរបប លន់ នល់ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[35]។

១៨. ទាក់ទងនឹងអតីតអ្នកទោស សហព្រះរាជអាជ្ញាលើកឡើងថា ជនជាប់ចោទមិនត្រូវចោទប្រកាន់ពីឧក្រិដ្ឋកម្មនៃអំពើហិង្សាផ្លូវភេទ*ដោយផ្ទាល់* ទេ ហើយហេតុនេះ មិនចាំបាច់ស្ដាប់សក្ខីកម្ម មាស សារ៉ាត់ (2-TCW-821) និង ហ៊ុន គីមសេង (2-TCW-1018) ឡើយ។ ផ្ទុយទៅវិញ ពួកគេយល់ស្របថា ការស្ដាប់សក្ខីកម្ម អ៊ុច ហាន (2-TCW-1019) និង វង្ស សារុន (2-TCW-986) មានភាពសមស្របជាង។ ពួកគេមិនបានធ្វើសេចក្ដីសន្និដ្ឋានទាក់ទងនឹង សែត យែម (2-TCCP-1020) ឡើយ[36]។

១៩. ពាក់ព័ន្ធនឹងសំណើសុំកោះហៅអតីតបុគ្គលិកនៅក្រាំងតាចាន់បន្ថែម សហព្រះរាជអាជ្ញាលើកឡើងថា ពួកគេមិនបានដឹងថាតើ តូច (2-TCW-1022) និង អ៊ួក (2-TCW-1023) នៅរស់ ឬស្លាប់ទេ ចំណែកចម្លើយរបស់ សាំង ស៊ីម (2-TCW-1021) ត្រូវបានយកមកប្រើប្រាស់យ៉ាងទូលំទូលាយ និងយកមកអាននៅក្នុងតុលាការទៀតផង។ ហេតុនេះ វត្តមានរបស់គាត់មិនមានអ្វីបន្ថែមលើភស្តុតាងដែលមានស្រាប់នៅចំពោះមុខអង្គជំនុំជម្រះនោះទេ[37]។

២០. ពាក់ព័ន្ធនឹងអតីតកម្មាភិបាលស្រុកត្រាំកក់ សហព្រះរាជអាជ្ញាយល់ស្របថា ទឹម ហ៊ី (2-TCW-833) គួរតែត្រូវបានស្ដាប់សក្ខីកម្ម។ ក៏ប៉ុន្តែ ពួកគេលើកឡើងថា គាត់គួរត្រូវបានកោះហៅមកផ្ដល់

---

[34] ប្រតិចារឹកសវនាការ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥ ទំព័រ ៦៥ ដល់ ៦៦។

[35] ប្រតិចារឹកសវនាការ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥ ទំព័រ ១៧។

[36] ប្រតិចារឹកសវនាការ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥ ទំព័រ ៦៥ ដល់ ៦៦។

[37] ប្រតិចារឹកសវនាការ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥ ទំព័រ ៦៦។

សក្ខីកម្មក្នុងអំឡុងពេលនៃអង្គហេតុស្តីពីការបោសសម្អាតផ្ទៃក្នុង។ ពួកគេមិនបានធ្វើសេចក្តីសន្និដ្ឋានទាក់ទងនឹង សាន់ ឡួន (2-TCW-1007) ទេ[38]។

២១. សហព្រះរាជអាជ្ញាលើកឡើងថា សក្ខីកម្មរបស់ ជាំង ស្រីមុំ ស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំរបស់គាត់មានភាពច្បាស់លាស់ ហើយហេតុនេះ មិនចាំបាច់កោះហៅ ទ្រី ទូច (2-TCW-1024) មកផ្តល់សក្ខីកម្មបន្ថែមលើ សេង អុល (2-TCW-1025) ទេ[39]។

២២. ទាក់ទងនឹងឯកសារនានានៅក្រាំងតាចាន់ សហព្រះរាជអាជ្ញាឆ្លើយតបថា ធ្លាប់មានសវនាការទៅលើប្រធានបទនេះរួចមកហើយ នៅក្នុងសំណុំរឿង ០០២/០១ ហើយការស្នើសុំកោះហៅសាក្សីថ្មីដូចជាពុំបន្ថែមអ្វីច្រើនទេ។ ជាងនេះទៀត ភ័ស្តុតាងដែលបង្ហាញពីយថាភាពនៃឯកសារក៏ត្រូវបានស្តាប់រួចហើយដែរ[40]។

## ២.៣ ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

២៣. សហមេធាវីនាំមុខពឹងផ្អែកលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងបញ្ហាថាតើ គួរកោះហៅ ឬមិនគួរកោះហៅ សៅ វ៉ន (2-TCW-989) ឱ្យមកផ្តល់សក្ខីកម្ម តែកត់សម្គាល់ថា មេធាវីការពារក្តី នួន ជា ធ្លាប់មាន និងនៅតែមានចម្លើយរបស់គាត់ដើម្បីយកមកប្រើប្រាស់ក្នុងអំឡុងពេលសួរដេញដោលសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនដែលបានមកផ្តល់សក្ខីកម្មស្តីពីការប្រព្រឹត្តិចំពោះអតីតទាហាន និងអ្នករដ្ឋការរបប លន់ នល់[41]។

២៤. ទាក់ទងនឹង មាស សាវ៉ាត់ (2-TCW-821) សហមេធាវីនាំមុខកត់សម្គាល់ថា សក្ខីកម្មរបស់គាត់នឹងត្រួតគ្នាជាមួយនឹងសក្ខីកម្មរបស់សាក្សីផ្សេងៗទៀត ស្តីពីស្ថានភាពនៃការឃុំឃាំងនៅក្រាំងតាចាន់ ហើយថា ការបៀតបៀនផ្លូវភេទមកលើរូបគាត់ ត្រូវបានពិភាក្សាជាច្រើនមកហើយ[42]។

---

38 ប្រតិចារឹកសវនាការ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥ ទំព័រ ៦៦។

39 ប្រតិចារឹកសវនាការ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥ ទំព័រ ៦៧។

40 ប្រតិចារឹកសវនាការ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥ ទំព័រ ៦៧។

41 ចម្លើយតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ១៦។

42 ចម្លើយតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ១៧។

សហមេធាវីនាំមុខលើកឡើងបន្ថែមថា សក្ខីកម្មរបស់ ហ៊ិន គឹមសេង (2-TCW-1018), អ៊ួច ហាន (2-TCW-1019) និង វង្ស សារុន (2-TCW-986) នឹងជាការច្រំដែល និងត្រួតគ្នាជាមួយសក្ខីកម្មនានាដែលបានផ្តល់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ[43]។ ទាក់ទងនឹង សែត យែម (2-TCCP-1020) និងការអះអាងរបស់គាត់ដែលថា អាចមានករណីដែលថា អ្នកទោសត្រូវបានដោះលែងចេញពីមន្ទីរសន្តិសុខនោះ សហមេធាវីនាំមុខកត់សម្គាល់ថា ដីកាដំណោះស្រាយលើកឡើងយ៉ាងច្បាស់ថា សាក្សីប្រាំមួយរូបត្រូវបានដោះលែងចេញពីក្រាំងតាចាន់។ ពួកគេក៏កត់សម្គាល់ផងដែរថា អង្គជំនុំជម្រះបានកោះហៅសាក្សីពីររូបក្នុងចំណោមសាក្សីទាំងនេះ មកផ្តល់សក្ខីកម្មរួចហើយ ដោយផ្តល់ឱកាសឲ្យមេធាវីការពារក្តី នួន ជា សាកសួរពួកគេទៅលើបញ្ហានេះ[44]។

២៥. សហមេធាវីនាំមុខឆ្លើយតបថា សក្ខីកម្មរបស់អតីតបុគ្គលិកក្រាំងតាចាន់បន្ថែម រួមមាន សាំង ស៊ីម (2-TCW-1021), គួច (2-TCW-1022) និង អ៊ួក (2-TCW-1023) ទំនងជាស៊ីសង្វាក់គ្នា ឬច្រំដែលទៅនឹងភស្តុតាងផ្សេងទៀតដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ។ សហមេធាវីនាំមុខពឹងផ្អែកលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងបញ្ហាថាតើគួរកោះហៅ ឬមិនគួរកោះហៅបុគ្គលទាំងនេះឲ្យមកផ្តល់សក្ខីកម្ម[45]។

២៦. ទាក់ទងនឹងអតីតកម្មាភិបាលពីររូបនៅត្រាំកក់ សហមេធាវីនាំមុខកត់សម្គាល់ថា សក្ខីកម្មរបស់ សាន់ ឡុន (2-TCW-1007) ទំនងជាត្រួតគ្នាទៅនឹងសក្ខីកម្មរបស់ ខឹម បឿន (2-TCW-979) ចំណែក ទឹម ហ៊ី (2-TCW-833) មានឈ្មោះនៅក្នុងបញ្ជីឈ្មោះសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានកោះហៅរួចហើយ[46]។

២៧. ជាចុងក្រោយ សហមេធាវីនាំមុខលើកឡើងថា សំណើសុំកោះហៅសាក្សីពីររូបឲ្យមកផ្តល់សក្ខីកម្មស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមិនត្រូវបានដាក់ទាន់ពេលវេលាទេ។ ក្រៅពីនេះ ទាក់ទងនឹង ទ្រី ទូច (2-TCW-1024) ពួកគេលើកជាទឡ្ហីករណ៍ថា សក្ខីកម្មរបស់គាត់ទំនងត្រួតគ្នាជាមួយ

---

[43] ចម្លើយតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ១៨ ដល់ ១៩។

[44] ចម្លើយតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ២០។

[45] ចម្លើយតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ២១។

[46] ចម្លើយតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ២២។

សក្ខីកម្មរបស់សាក្សីនានាដែលបានផ្តល់រួចហើយ។ សហមេធាវីនាំមុខក៏កត់សម្គាល់ផងដែរថា អង្គហេតុនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាអង្គហេតុមួយដោយឡែក ហើយថា បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលពួកគេបានស្នើសម្រាប់អង្គហេតុនេះ រួមមានទាំងបុរស និងស្ត្រី ដែលនឹងមកផ្តល់សក្ខីកម្មស្តីពីបញ្ហានេះ[47]។

២៨. សហមេធាវីនាំមុខមិនបានធ្វើសេចក្តីសន្និដ្ឋានទាក់ទងនឹង អ៊ុំ សារិ (2-TCW-1026) និង ស៊ូ ភីរិន្ទ (2-TCW-1027) នោះទេ។

## ៣. ក្របខ័ណ្ឌគតិយុត្តិ

២៩. អង្គជំនុំជម្រះសាលាដំបូងរំលឹកថា អនុលោមតាមក្របខ័ណ្ឌគតិយុត្តិនៅ អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូងត្រូវជ្រើសរើសបុគ្គលទាំងឡាយណាឱ្យមកផ្តល់សក្ខីកម្ម ដែលអង្គជំនុំជម្រះចាត់ទុកថាពិតជាអាចនាំទៅរកការបង្ហាញការពិត ដោយស្របទៅនឹងលក្ខខណ្ឌតម្រូវរួមដែលថា កិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក "ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ" ហើយថា "ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប"[48]។ អង្គជំនុំជម្រះក៏អាចស្តាប់សក្ខីកម្មរបស់អ្នកជំនាញអំពីប្រធានបទណាមួយដែលចាត់ទុកថាសំខាន់នៅក្នុងសវនាការ[49]។

៣០. អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះអាចបដិសេធមិនស្តាប់សក្ខីកម្មដែល (ក) មិនជាប់ពាក់ព័ន្ធ ឬជាន់គ្នា (ខ) មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ (គ) មិន

---

[47] ចម្លើយតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ២៣។

[48] វិធាន ២១(១)(ក) និង ២១(៤) នៃវិធានផ្ទៃក្នុង។ សូមមើល ផងដែរ វិធាន ៨៥ នៃវិធានផ្ទៃក្នុង (ដែលចែងថា ប្រធានអង្គជំនុំជម្រះសាលាដំបូងត្រូវធានាដល់ការអនុវត្តសិទ្ធិការពារខ្លួនឱ្យប្រព្រឹត្តទៅបានដោយសេរី និងអាចបដិសេធនូវរាល់នីតិវិធីដែលនាំឱ្យមានការពន្យារពេលដល់ការជំនុំជម្រះ និងដែលមិនអាចនាំទៅដល់ការស្វែងរកការពិត)។ *សូមមើល* សេចក្តីសម្រេចស្តាពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E312 ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ២២។

[49] វិធាន ៣១(១) នៃវិធានផ្ទៃក្នុង។ សូមមើល សេចក្តីសម្រេចស្តាពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E312 ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ២២។

សមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំឱ្យពិនិត្យភស្តុតាង (ឃ) ច្បាប់មិនអនុញ្ញាត ឬ (ង) មានចេតនាពន្យារពេលកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍[50]។

៣១. អង្គជំនុំជម្រះសាលាដំបូងរំលឹកបន្ថែមទៀតថា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះអាចទទួលយកភស្តុតាងថ្មីដែលអាចនាំទៅដល់ការស្វែងរកការពិត ប្រសិនបើភស្តុតាងនោះក៏បំពេញផងដែរទៅតាមលក្ខណៈវិនិច្ឆ័យនៃវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង រួមមាន បទដ្ឋាន *បឋម*នៃភាពជាប់ពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាព[51]។ ភាគីដែលស្នើសុំឱ្យទទួលយកភស្តុតាង ឬសក្ខីកម្មថ្មី ត្រូវស្នើសុំតាមរយៈសារណាដែលមានសំអាងហេតុ។ សំណើសុំឱ្យស្តាប់សក្ខីកម្មសាក្សីថ្មី ដើមបណ្តឹងរដ្ឋប្បវេណី និង/ឬអ្នកជំនាញ ត្រូវតែធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា

---

[50] វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា និងសំណើរបស់ ខៀវ សំផន អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ស្តីពីសារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិក (E282 និង E282/1, E290 និង E290/1) ឯកសារ E282/2 ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ៣។ *សូមមើល ផងដែរ* រឿងក្តី *កាំង ហ្គេកអ៊ាវ ហៅ ឌុច* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក (សំណុំរឿងលេខ ០០១/១៨ កក្កដា ២០០៧/អវតក/អជសដ) ឯកសារ E188 ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៤១។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Karemera* និងអ្នកផ្សេងទៀត សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ Mathieu Ngirumpatse ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨ តុលាការកំពូលនៃតុលាការ ICTR (សំណុំរឿង ICTR-98-44-AR73.14) ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ កថាខណ្ឌ ២៥ (ដោយបានសន្និដ្ឋានថា លក្ខណៈដដែលៗនៃសក្ខីកម្មត្រូវបានពិចារណាជាកត្តាមួយក្នុងការសម្រេចថាតើ ការស្តាប់សក្ខីកម្មនោះជាការចាំបាច់ ឬយ៉ាងណា)។ សូមមើល សេចក្តីសម្រេចស្តាពរស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E312 ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ២៣។

[51] ចម្លើយតបទៅនឹងសំណើតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញា ជនជាប់ចោទ នួន ជា និងខៀវ សំផន (E236/4/1. E265, E271, E276, E276/1) ឯកសារ E276/2 ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ២។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា និងសំណើរបស់ ខៀវ សំផន អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ស្តីពីសារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិក (E282 និង E282/1, E290 និង E290/1) ឯកសារ E282/2 ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ៣។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកឯកសារពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ អនុលោមតាមវិធាន ៨៧(៣) និងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង - សម្ងាត់ ឯកសារ E319/11/1 ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ កថាខណ្ឌ ២។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យទទួលយកឯកសារដែលទាក់ទងនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ និងសេចក្តីបង្គាប់ស្តីពីការប្រើប្រាស់កំណត់ហេតុនៃការស្តាប់ចម្លើយក្នុងសំណុំរឿង ០០៣ និង ០០៤ ឯកសារ E319/7 ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ៩។ សំអាងហេតុសម្រាប់សេចក្តីសម្រេចលើសំណើរួមរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំស្តាប់សាក្សីបន្ថែមសម្រាប់សវនាការវគ្គដំបូងនៃសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ និងសេចក្តីសម្រេចលើសាក្សីឈ្មោះ សាន់ ឡូន (2-TCW-1007) ស៊ូ ភីរិន្ទ (2-TCW-1027) និង អ៊ីវ សារិ (2-TCW-1026)

សក្ខីកម្មថ្មីដែលបានស្នើសុំ រកមិនឃើញនៅមុនពេលចាប់ផ្តើមការជំនុំជម្រះ ឬមិនអាចរកបាន ទោះបីជាមានការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក៏ដោយ[52]។ ប្រសិនបើភាគីខកខានមិនបានបំពេញលក្ខខណ្ឌដូច្នេះទេ អង្គជំនុំជម្រះអាចបដិសេធសំណើសុំបែបនេះភ្លាមៗតែម្តង។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងករណីមួយចំនួន អង្គជំនុំជម្រះបានទទួលយកភស្តុតាង ដែលនិយាយឲ្យសាមញ្ញទៅ មិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យនេះឡើយ ដែលក្នុងនោះរួមមានករណីដែលភស្តុតាងពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងសម្ភារៈដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ និងនៅក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឲ្យវាយតម្លៃរួមគ្នាលើប្រភពនៃភស្តុតាង និងក្នុងករណីដែលឯកសារដែលបានស្នើសុំនោះ គឺជាឯកសារដោះបន្ទុក ហើយតម្រូវឲ្យវាយតម្លៃដើម្បីជៀសវាងនូវភាពមិនត្រឹមត្រូវក្នុងការស្វែងរកយុត្តិធម៌[53]។

---

[52] ចម្លើយតបទៅនឹងសំណើតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញា ជនជាប់ចោទ នួន ជា និង ខៀវ សំផន (E236/4/1. E265, E271, E276, E276/1) ឯកសារ E276/2 ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ៣។ ចម្លើយតបទៅនឹងសំណើតាមវិធាន ៨៧(៤) សុំដាក់ឯកសារថ្មីទៅក្នុងសំណុំរឿងពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សីលោក François PONCHAUD និងលោក Sydney SCANBERG (E243) ព្រមទាំងអ្នកជំនាញ លោក Philip SHORT (E226, 226/1 និង 230) និងលោកស្រី Elizabeth BECKER (E232 និង E232/1) ឯកសារ E260 ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៥។ សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨៧(៤) ពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី D22/2500 ដោយភ្ជាប់ជាមួយឧបសម្ព័ន្ធ ក សម្ងាត់ ឯកសារ E344/1 ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៥ កថាខណ្ឌ ២។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យទទួលយកឯកសារដែលទាក់ទងនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ និងសេចក្តីបង្គាប់ស្តីពីការប្រើប្រាស់កំណត់ហេតុនៃការស្តាប់ចម្លើយក្នុងសំណុំរឿង ០០៣ និង ០០៤ ឯកសារ E319/7 ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ៩។ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។

[53] ចម្លើយតបទៅនឹងសំណើតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញា ជនជាប់ចោទ នួន ជា និងខៀវ សំផន (E236/4/1. E265, E271, E276, E276/1) ឯកសារ E276/2 ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ២។ ចម្លើយតបទៅនឹងសំណើតាមវិធាន ៨៧(៤) សុំដាក់ឯកសារថ្មីទៅក្នុងសំណុំរឿងពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សីលោក François PONCHAUD និងលោក Sydney SCANBERG (E243) ព្រមទាំងអ្នកជំនាញ លោក Philip SHORT (E226, 226/1 និង 230) និងលោកស្រី Elizabeth BECKER (E232 និង E232/1) ឯកសារ E260 ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៥។ សេចក្តីសម្រេចលើសំណើរបស់ នួន ជា តាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងសុំឲ្យទទួលយកសារទូរលេខតាមផ្លូវទូតចំនួន ១១ (E383) ឯកសារ E383/2 ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៣។

៣២. អង្គជំនុំជម្រះសាលាដំបូងក៏ពិចារណាផងដែរអំពីវិយជារបស់ជនជាប់ចោទ សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី និងចងចាំជានិច្ចថា កិច្ចដំណើរការនីតិវិធី ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ និងចាំបាច់ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប[54]។

## ៤. <u>សំអាងហេតុ</u>

### <u>៤.១. ការប្រព្រឹត្តិលើអតីតអ្នករដ្ឋការ និងទាហានរបប លន់ នល់ - សៅ វ៉ន (2-TCW-989)</u>

៣៣. អង្គជំនុំជម្រះកត់សម្គាល់ថា ចម្លើយរបស់ សៅ វ៉ន (2-TCW-989) អាចឱ្យមេធាវីការពារក្ដីរកមើលបានចាប់ពីថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៣[55] ដូច្នេះហើយចម្លើយនេះមិនអាចរកមើលបានទេនៅមុខពេលចាប់ផ្ដើមការជំនុំជម្រះនៅក្នុងឆ្នាំ ២០១១។ ទោះបីជាយ៉ាងណាក៏ដោយ មេធាវីការពារក្ដី នួន ជា ត្រូវបានតម្រូវឱ្យធ្វើការស្នើសុំសាក្សីបន្ថែមនេះឱ្យបានទាន់ពេលវេលា ប៉ុន្តែមេធាវីការពារក្ដីខកខានមិនបានបំពេញកាតព្វកិច្ចនេះទេ។ ទោះបីជាមានសិទ្ធិចូលពិនិត្យមើលចម្លើយនេះចាប់ពីថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៣ ក៏ដោយ ក៏មេធាវីការពារក្ដី នួន ជា អះអាងថា ទើបតែបានដឹងពីសាក្សីរូបនេះ និងសារៈសំខាន់របស់គាត់នៅក្នុងអំឡុងពេលនៃការរៀបចំសារណាបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ("សារណាបណ្ដឹងសាទុក្ខ")[56]។ ទោះបីជាសារណាបណ្ដឹងសាទុក្ខត្រូវបានដាក់នៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ មុនពេលចាប់ផ្ដើមសវនាការលើអង្គហេតុសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ក៏ដោយ ក៏មេធាវីការពារក្ដី នួន ជា មិនបានធ្វើការស្នើសុំឱ្យស្ដាប់សក្ខីកម្មសាក្សីរូបនេះនៅក្នុងសំណុំរឿង ០០២/០២ ឡើយ រហូតដល់ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៥ គឺនៅពេលដែលអង្គជំនុំជម្រះជិតនឹងបញ្ចប់សវនាការលើអង្គ-

---

[54] *សូមមើល* សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវស្ដាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E312 ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ២២។

[55] អនុស្សរណៈរបស់អង្គជំនុំជម្រះដែលមានចំណងជើងថា "ការទទួលយកកំណត់ហេតុស្ដាប់ចម្លើយក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២ ឯកសារ E127/7/2 ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៣។

[56] អង្គជំនុំជម្រះកត់សម្គាល់ថា សាក្សីរូបនេះបានចូលមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក នៅថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ F1/1.1។

ហេតុនេះទៅហើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា មេធាវីការពារក្ដី នួន ជា ខកខាន មិនបានធ្វើការខិតខំប្រឹងប្រែងឱ្យបានសមស្របឡើយ និងយល់ឃើញថា សំណើសុំពាក់ព័ន្ធនឹងសាក្សីរូបនេះ មិនបានធ្វើឡើងឱ្យបានទាន់ពេលវេលានោះទេ។

៣៤. ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះរំលឹកថា ប្រសិនបើសំណើសុំមិនបានបំពេញនូវលក្ខខណ្ឌតម្រូវតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងនោះទេ អង្គជំនុំជម្រះនៅតែអាចទទួលយកភស្តុតាង ក្នុងករណីដែលមានតម្រូវដូច្នេះដើម្បីផលប្រយោជន៍យុត្តិធម៌ ជាពិសេសនៅពេលដែលភស្តុតាងនោះគឺជាឯកសារដោះបន្ទុកដែលតម្រូវឱ្យមានការពិនិត្យដើម្បីជៀសវាងនូវភាពមិនត្រឹមត្រូវក្នុងការស្វែងរកយុត្តិធម៌។ អង្គជំនុំជម្រះកត់សម្គាល់ថា ពុំមានភាគីណាមួយជំទាស់ទៅនឹងការស្នើសុំបន្ថែមសាក្សីរូបនេះទេ។ ដោយពិចារណាថា សាក្សីរូបនេះអាចផ្ដល់នូវភស្តុតាងដោះបន្ទុកជាសក្ដានុពលនោះ អង្គជំនុំជម្រះយល់ស្របតាមសំណើរបស់មេធាវីការពារក្ដី នួន ជា។ ទោះបីជាយ៉ាងណាក៏ដោយ ដោយពិចារណាថា អង្គហេតុស្ដីអំពីការប្រព្រឹត្តិលើអតីតទាហានរបប លន់ នល់ អង្គជំនុំជម្រះយល់ឃើញថា វាជាការសមស្របក្នុងការស្ដាប់សក្ខីកម្មរបស់ សៅ វ៉ន (2-TCW-989) នៅដំណាក់កាលនេះ។ ដូច្នេះ អង្គជំនុំជម្រះសម្រេចស្ដាប់សក្ខីកម្មរបស់ សៅ វ៉ន (2-TCW-989) នៅក្នុងអំឡុងពេលសវនាការពាក់ព័ន្ធនឹងអង្គហេតុស្ដីអំពីការប្រព្រឹត្តិលើអតីតមន្ត្រីរដ្ឋការរបបសាធារណរដ្ឋខ្មែរ[57]។

## ៤.២. អតីតអ្នកទោសក្រាំងតាចាន់

### ៤.២.១. *មាស សារ៉ាត់ (2-TCW-821) និង ប៉ុន គីមសេង (2-TCW-1018)*

៣៥. អង្គជំនុំជម្រះកត់សម្គាល់ថា មាស សារ៉ាត់ (2-TCW-821) គឺជាសាក្សីបម្រុងនៅក្នុងបញ្ជីឈ្មោះសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើឡើងដោយ ក.ស.ព[58]។ ទោះបីជាលោក

---

[57] អង្គជំនុំជម្រះកត់សម្គាល់ថា សៅ វ៉ន (2-TCW-989) បានផ្ដល់សក្ខីកម្មកាលពីមុនក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៦ សូមមើលប្រតិចារឹក ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៦ (សៅ វ៉ន)។

[58] ឧបសម្ព័ន្ធសម្ងាត់ I៖ បញ្ជីឈ្មោះរួមបញ្ចូលគ្នារបស់សហព្រះរាជអាជ្ញាអំពីសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញសម្រាប់សវនាការសំណុំរឿង ០០២/០២ តាមលំដាប់លំដោយដែលបានស្នើសម្រាប់វគ្គសវនាការ និងការចូលខ្លួន ឯកសារ E305/6.1 ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤។ ឧបសម្ព័ន្ធ I៖ បញ្ជីឈ្មោះរួមបញ្ចូលគ្នាដែលបានកែសម្រួលរបស់សហព្រះរាជអាជ្ញា សំអាងហេតុសម្រាប់សេចក្ដីសម្រេចលើសំណើរួមរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំស្ដាប់សាក្សីបន្ថែមសម្រាប់សវនាការវគ្គដំបូងនៃសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ និងសេចក្ដីសម្រេចលើសាក្សីឈ្មោះ សាន់ ឡូន (2-TCW-1007) ស៊ូ ភីរិន្ទ (2-TCW-1027) និង អ៊ីវ សារិ (2-TCW-1026)

ស្រីមិនត្រូវបាន ក.ស.ច.ស ស្តាប់ចម្លើយក៏ដោយ ក៏សេចក្តីសង្ខេបនៃភស្តុតាងដែលទាក់ទងនឹងលោកស្រី អាចឱ្យមេធាវីការពារក្តី នួន ជា រកមើលបាន យ៉ាងហោចណាស់ចាប់តាំងពី ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤[59]។ ពាក់ព័ន្ធនឹង ហ៊ុន គីមសេង (2-TCW-1018) អង្គជំនុំជម្រះកត់សម្គាល់ថា តាមរយៈការទទួលស្គាល់ដោយផ្ទាល់របស់មេធាវីការពារក្តី នួន ជា មេធាវីការពារក្តី បានដឹងអំពីអត្ថិភាពនៃសក្ខីកម្មរបស់លោកស្រីនៅមុនពេលចាប់ផ្តើមសវនាការក្នុងឆ្នាំ ២០១១[60]។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា មេធាវីការពារក្តី នួន ជា ខកខានមិនបានធ្វើការខិតខំប្រឹងប្រែងឱ្យបានសមស្របឡើយ និងយល់ឃើញថា សំណើសុំពាក់ព័ន្ធនឹងសាក្សីទាំងពីររូបនេះ មិនបានធ្វើឡើងឱ្យបានទាន់ពេលវេលានោះឡើយ ហើយដោយផ្អែកលើមូលដ្ឋាននេះ សំណើសុំនេះអាចត្រូវបានបដិសេធភ្លាមៗ។

៣៦. អង្គជំនុំជម្រះយល់ឃើញទៀតថា មេធាវីការពារក្តី នួន ជា ខកខានមិនបានបង្ហាញថា ទោះបីជាយ៉ាងណាក្តីសក្ខីកម្មទាំងនេះគួរត្រូវបានស្តាប់ដើម្បីផលប្រយោជន៍យុត្តិធម៌ ឬក៏ថា ពួកគាត់ផ្តល់នូវសម្ភារៈដោះបន្ទុកដ៏សំខាន់ដែលគួរត្រូវយកមកពិនិត្យ ដើម្បីជៀសវាងនូវភាពមិនត្រឹមត្រូវក្នុងការស្វែងរកយុត្តិធម៌នោះឡើយ។ ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះធ្លាប់បានសម្រេចពីមុនហើយថា ទោះបីជាហេតុការណ៍នៃការរំលោភផ្លូវភេទអាចពាក់ព័ន្ធ ក្នុងចំណោមការពាក់ព័ន្ធផ្សេងទៀត ទៅនឹងលក្ខខណ្ឌនៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ក៏ដោយ ក៏ជនជាប់ចោទនៅក្នុងសំណុំរឿង ០០២/០២ មិនត្រូវបានចោទប្រកាន់អំពីបទរំលោភផ្លូវភេទ នៅក្រៅបរិបទនៃការរៀបការដោយបង្ខំនោះទេ[61]។ លើសពីនេះទៀត អង្គជំនុំជម្រះបានស្តាប់រួចហើយនូវការបង្ហាញភស្តុតាងផ្ទាល់អំពីបញ្ហាផ្សេងៗទៀត ដែលមេធាវីការពារក្តី នួន ជា អះអាងថា សាក្សីទាំងនេះអាចផ្តល់នូវការបញ្ជាក់បំភ្លឺ

---

អំពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសម្រាប់សវនាការសំណុំរឿង ០០២/០២ តាមលំដាប់លំដោយដែលបានស្នើសម្រាប់វគ្គសវនាការ និងការចូលខ្លួន (ខែ កក្កដា ឆ្នាំ ២០១៤) ឯកសារ E307/3/2.2 ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៤។

59 ឧបសម្ព័ន្ធសម្ងាត់ IIIក៖ សេចក្តីសង្ខេបដែលបានធ្វើបច្ចុប្បន្នភាពរបស់ ក.ស.ព អំពីសាក្សីបម្រុង ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ [បម្រុង] ឯកសារ E305/6.5 ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ ៣។

60 *សូមមើល* សំណើ កថាខណ្ឌ ១១។

61 សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឱ្យមានការតទល់គ្នារវាងដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ជាមួយនឹងសាក្សីស្រី ថន និងដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង និងស្នើសុំឯកសារថតចម្លងនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ឯកសារ E348/4 ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥ កថាខណ្ឌ ១១។

ឲ្យបានច្បាស់ ហើយផ្ទុយទៅនឹងការអះអាងរបស់មេធាវីការពារក្តី នួន ជា អង្គជំនុំជម្រះយល់ឃើញថា ភស្តុតាងនេះមានភាពស៊ីសង្វាក់គ្នាច្រើនដែរហើយទៅលើបញ្ហាទាំងនេះ។ សក្ខីកម្មដែលបានស្នើឡើងរបស់សាក្សីទាំងនេះ ទំនងជាមានលក្ខណៈច្រំដែលជាមួយនឹងសក្ខីកម្មដែលមានរួចហើយនៅចំពោះមុខអង្គជំនុំជម្រះ[62]។

៣៧. យោងទៅលើហេតុផលខាងលើនេះ សំណើរបស់ នួន ជា ទាក់ទងនឹង មាស សាវ៉ាត់ (2-TCW-821) និង ហ៊ុន គីមសេង (2-TCW-1018 ) ត្រូវបានបដិសេធចោល។

### ៤.២.២. *វង្ស សារុន (2-TCW-986) និង អ៊ួច ហាន (2-TCW-1019)*

៣៨. អង្គជំនុំជម្រះកត់សម្គាល់ថា ទាំងអ៊ួច ហាន (2-TCW-1019) ទាំង វង្ស សារុន (2-TCW-986) មិនត្រូវបាន ក.ស.ច.ស ស្តាប់ចម្លើយ ឬក៏ភាគីណាមួយកំណត់អត្តសញ្ញាណថាជាសាក្សីសក្តានុពលនៅក្នុងរឿងក្តីនេះឡើយ ហើយថា ពុំមានចម្លើយផ្សេងទៀតរបស់សាក្សីដែលបានស្នើឡើងទាំងពីររូបនេះនៅក្នុងសំណុំរឿងឡើយ។ ព័ត៌មានស្តីអំពីទីកន្លែងរបស់ពួកគាត់បានលេចចេញនៅក្នុងអំឡុងពេលសវនាការ[63]។ ដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា សក្ខីកម្មរបស់សាក្សីដែលបានស្នើឡើងទាំងពីររូបនេះ ពុំអាចរកបានឡើយនៅមុនពេលចាប់ផ្តើមសវនាការនៅក្នុងខែ មិថុនា ឆ្នាំ ២០១១ ឬនៅពេលដែលភាគីបានដាក់បញ្ជីឈ្មោះដែលបានកែសម្រួលរបស់ពួកគេនោះទេ[64]។

---

[62] *សូមមើល* ប្រតិចារឹក ថ្ងៃទី ២១-២២ ខែ មករា ឆ្នាំ ២០១៥ (មាស សុខា)។ ប្រតិចារឹក ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៥ (កែវ ចាន់តារា)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ (កែវ ចាន់តារា)។ ប្រតិចារឹក ថ្ងៃទី ០៤-០៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ (សយ សែន)។ ប្រតិចារឹក ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥ (វង្ស សារុន)។

[63] ប្រតិចារឹក ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៥ (សយ សែន) ទំព័រ ៨៦-៩១ (ភាសាអង់គ្លេស)។

[64] *សូមមើល* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា “សេចក្តីសម្រេចលើសំណើរួមសុំឲ្យសម្រេចសាជាថ្មីឡើងវិញលើការអនុវត្តវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង” ឯកសារ E307/1/2 ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤កថាខណ្ឌ ១០-១១។ នៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យភាគីទាំងអស់ដាក់បញ្ជីឈ្មោះដែលបានធ្វើបច្ចុប្បន្នភាព និងសេចក្តីសង្ខេបអំពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើឡើងសម្រាប់សំណុំរឿង ០០២/០២ (“បញ្ជីឈ្មោះដែលបានកែសម្រួល”) ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដែលបានធ្វើបច្ចុប្បន្នភាពដើម្បីរៀបចំសវនាការក្នុងសំណុំរឿង ០០២/០២ ឯកសារ E305 ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៤ កថាខណ្ឌ ១-៨។ សូមមើល បញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា និងសេចក្តីសង្ខេបសម្រាប់ជំនុំជម្រះក្នុងសំណុំរឿងលេខសំអាងហេតុសម្រាប់សេចក្តីសម្រេចលើសំណើរួមរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំស្តាប់សាក្សីបន្ថែមសម្រាប់សវនាការវគ្គដំបូងនៃសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ និងសេចក្តីសម្រេចលើសាក្សីឈ្មោះ សាន់ ឡុន (2-TCW-1007) ស៊ូ ភីរិន្ទ (2-TCW-1027) និង អ៊ីវ សារិ (2-TCW-1026)

៣៩. អង្គជំនុំជម្រះយល់ឃើញថា ទោះបីជាសក្ខីកម្មរបស់សាក្សីដែលបានស្នើឡើងទាំងពីររូបនេះពាក់ព័ន្ធនឹងក្រាំងតាចាន់ ទំនងជាមានលក្ខណៈច្រំដែលច្រើនជាមួយនឹងសក្ខីកម្មផ្ទាល់ដែលអង្គជំនុំជម្រះបានស្តាប់រួចហើយ[65] ក៏ដោយ ក៏សក្ខីកម្មនេះអាចផ្តល់នូវការយល់ដឹងបន្ថែមទៀតអំពីស្ថានភាព និងការព្យាបាលផ្នែកវេជ្ជសាស្ត្រ ដែលអាចជួយដល់អង្គជំនុំជម្រះក្នុងការស្វែងរកការពិត។ ដោយពិចារណាថា វង្ស សារុន (2-TCW-986) អាចមានលទ្ធភាពផ្តល់នូវការយល់ដឹងបន្ថែមទៀតអំពីតួនាទីរបស់ប្រធានគុក តា អាន អង្គជំនុំជម្រះ ជ្រើសរើសយក វង្ស សារុន (2-TCW-986) ឱ្យមកផ្តល់សក្ខីកម្ម[66]។ អង្គជំនុំជម្រះបដិសេធសំណើពាក់ព័ន្ធនឹង អ៊ួច ហាន (2-TCW-1019) ដោយសារតែផ្អែកទៅលើតួនាទីរបស់គាត់នៅពេលនោះ សក្ខីកម្មរបស់គាត់គឺទំនងជាមានលក្ខណៈច្រំដែលជាមួយនឹងសក្ខីកម្មរបស់ វង្ស សារុន (2-TCW-986)។

### ៤.២.៣. *សែត យ៉ែម*

៤០. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សែត យ៉ែម (2-TCCP-1020) ត្រូវបានកត់ត្រាទុក នៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៤ ហើយត្រូវបាន

---

០០២/០២ (ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ចំនួន៥ I, II, IIក, III និង IIIក) ឯកសារ E305/6 ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤ ដោយភ្ជាប់ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ E305/6.1, E305/6.2, E305/6.3, E305/6.4, E305/6.5។ បញ្ជីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហមេធាវីនាំមុខតំណាងដើម បណ្តឹងរដ្ឋប្បវេណីសម្រាប់សំណុំរឿង ០០២/០២ អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង ជាមួយឧបសម្ព័ន្ធសម្ងាត់ ឯកសារ E305/7 ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤ ភ្ជាប់ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ E305/7.1, E305/7.1.1, E305/7.1.2។ សាក្សី និងអ្នកជំនាញស្នើឡើងដោយមេធាវីការពារក្តីលោក ខៀវ សំផន សម្រាប់សំណុំរឿង ០០២/០២ ឯកសារ E305/5 ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤ ភ្ជាប់ជាមួយនឹង ឧបសម្ព័ន្ធសម្ងាត់ E305/4.1, E305/4.2។ សូមមើល ផងដែរ សេចក្តីបន្ថែមទៅនឹងបញ្ជីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សំណុំរឿង ០០២/០២ អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង ជាមួយឧបសម្ព័ន្ធសម្ងាត់ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ E305/7/4 ភ្ជាប់ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ E305/7/4.1។

[65] *សូមមើល* ប្រតិចារឹក ថ្ងៃទី២១-២២ ខែ មករា ឆ្នាំ ២០១៥ (មាស សុខា)។ ប្រតិចារឹក ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៥ (កែវ ចាន់តារា)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ (កែវ ចាន់តារា)។ ប្រតិចារឹក ថ្ងៃទី ០៤-០៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ (សយ សែន)។ ប្រតិចារឹក ថ្ងៃទី ១៧-១៨ ខែ មីនា ឆ្នាំ ២០១៥ (រៀល សន)។

[66] វង្ស សារុន (2-TCW-986) បានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥ ប្រតិចារឹក ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥ (វង្ស សារុន)។

ដាក់បង្ហាញដល់មេធាវីការពារក្ដីនៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥[67]។ ដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា មេធាវីការពារក្ដីពុំអាចរកបានសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះនៅមុនពេលចាប់ផ្ដើមការជំនុំជម្រះ ឬ នៅត្រឹមពេលភាគីបានដាក់បញ្ជីកែសម្រួលរបស់ពួកគេនោះទេ។

៤១. ទោះបីជាយ៉ាងនេះក៏ដោយ ផ្ទុយពីសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដី នួន ជា បញ្ហាដែលដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានស្នើសុំឱ្យមកផ្ដល់សក្ខីកម្មពុំមែនជាបញ្ហាថ្មីនោះឡើយ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ដីកាដំណោះស្រាយលើកឡើងថា យ៉ាងហោចណាស់ សាក្សីចំនួន ៦ រូប ត្រូវបានដោះលែងពីក្រាំងតាចាន់[68] ក្នុងនោះមានសាក្សីចំនួន ២ រូប មាស សុខា (2-TCW-936) និង កែវ ច័ន្ទតារា (2-TCW-964) បានផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ ហើយបញ្ជាក់ថា ពួកគេត្រូវបានដោះលែងនៅក្រោយរយៈពេលនោះ[69]។ ទាក់ទងនឹងចំណុចផ្សេងទៀតដែលមេធាវីការពារក្ដីសន្និដ្ឋានថា ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះអាចផ្ដល់ការបញ្ជាក់បំភ្លឺបាននោះ អង្គជំនុំជម្រះយល់ឃើញថា អង្គជំនុំជម្រះបានស្ដាប់អង្គហេតុទាំងនេះច្រើនរួចហើយ ហើយសក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ដូចដែលបានស្នើឡើងទំនងជាច្រំដែលជាមួយនឹងសក្ខីកម្មសាក្សីដែលបានមកផ្ដល់សក្ខីកម្មរួចហើយនៅចំពោះមុខអង្គជំនុំជម្រះនេះ[70]។ ជាចុង

---

[67] កំណត់ហេតុសម្ភាត់បំផុតនៃការស្ដាប់ចម្លើយសាក្សី [ត្រូវបានកោសលុប] ឯកសារ E319/12.3.6 ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១៤។ សេចក្ដីជូនដំណឹងអំពី ខៀវ សំផន, នួន ជា សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីប្រចាំការទទួលយកឯកសារដែលបានដាក់បង្ហាញពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ ឯកសារ E319/12/1 ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១៥។

[68] ដីកាដំណោះស្រាយ កថាខណ្ឌ ៥០៥។

[69] ប្រតិចារឹក ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥ (មាស សុខា) ទំព័រ ៤១-៤២។ ប្រតិចារឹក ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១៥ (កែវ ច័ន្ទតារា) ទំព័រ ៤៩, ៥៣។ ប្រតិចារឹក ថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ (កែវ ច័ន្ទតារា) ទំព័រ ១៨ (សរុបចំនួន ២៤ ថ្ងៃ)។ សូមមើលផងដែរដីកាដំណោះស្រាយដែលបានយោងដោយផ្ទាល់លើការដោះលែង កែវ ច័ន្ទតារា ឯកសារ D427 កថាខណ្ឌ ៥០៥។

[70] *សូមមើល* ប្រតិចារឹក ថ្ងៃទី ២១ ដល់ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ (មាស សុខា) ទំព័រ ៤១-៤២។ ប្រតិចារឹក ថ្ងៃទី ៤ ដល់ថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ (សយ សែន)។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៥ (សយ សែន)។ ប្រតិចារឹក ថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ (កែវ ច័ន្ទតារា)។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៥ (សូត្រ សាំង)។ ប្រតិចារឹក ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ (វ៉ាន់ សឿន)។ ប្រតិចារឹក ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ (ស្រី ផន)។ ថ្ងៃទី ២៣ ដល់ ថ្ងៃទី ២៤ (ស្រី ផន) ស្ដីពីលក្ខខណ្ឌនៃការឃុំខ្លួន។ ស្ដីពីចំនួនអ្នកទោស និងរចនាសម្ព័ន្ធក្រាំងតាចាន់ សូមមើល ប្រតិចារឹក ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០១៥ (ស្រី ផន)។ ប្រតិចារឹក ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ (វ៉ាន់ សឿន)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស៊ាំង ស៊ឹម ឯកសារ D40/20 ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧។ ស្ដីពីរចនាសម្ព័ន្ធ/គំនូសទីតាំងក្រាំងតាចាន់ ប្រតិចារឹក ថ្ងៃទី ២៤ ខែមី

សំអាងហេតុសម្រាប់សេចក្ដីសម្រេចលើសំណើរួមរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំស្ដាប់សាក្សីបន្ថែមសម្រាប់សវនាការវគ្គដំបូងនៃសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ និងសេចក្ដីសម្រេចលើសាក្សីឈ្មោះ សាន់ ឡុន (2-TCW-1007) ស៊ូ គឹរិទ្ធ (2-TCW-1027) និង អ៊ុំ សារី (2-TCW-1026)

ក្រោយ ក្រោយពីបានពិនិត្យមើលចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីរួចហើយ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សែត យ៉ែម (2-TCCP-1020) នៅតែលើកឡើងដដែលថា គាត់ពុំបានស្គាល់ឈ្មោះអ្នកទាំងឡាយដែលធ្លាប់បានធ្វើការនៅក្រាំងតាចាន់ ហើយគាត់មានការភ័យខ្លាចរហូតមិនហ៊ានមើលពួកគេទេ[71]។ គាត់ក៏ពុំចងចាំថា នៅពេលណាគាត់ជាប់នៅក្រាំងតាចាន់ និងរយៈពេលប៉ុន្មានដែរ ហើយគាត់លើកឡើងទៀតថា គាត់ "ភាន់ភាំងអស់ហើយ" ក្រោយពេលកូនរបស់គាត់ស្លាប់នៅក្នុងមន្ទីរសន្តិសុខនោះ[72]។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា សក្ខីកម្មរបស់គាត់ដូចដែលបានស្នើសុំពុំបានបំពេញតាមលក្ខខណ្ឌនៃវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងនោះទេ ហើយវាពុំជួយដល់ការស្វែងរកការពិតផងដែរ។ យោងតាមមូលហេតុទាំងនេះ សំណើសុំរបស់ នួន ជា ទាក់ទងនឹង សែត យ៉ែម (2-TCCP-1020) ត្រូវបានច្រានចោល។

## ៤.៣. អតីតបុគ្គលិកក្រាំងតាចាន់-សាំង ស៊ីម (2-TCW-1021), ឡូច (2-TCW-1022) និង អ៊ិក (2-TCW-1023)

៤២. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មេធាវីការពារក្តី នួន ជា អាចរកបានកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាំង ស៊ីម (2-TCW-1021) នៅមុនពេលចាប់ផ្តើមការជំនុំជម្រះនៅក្នុងឆ្នាំ២០១១។ អង្គជំនុំជម្រះកត់សម្គាល់ឃើញទៀតថា ចម្លើយរបស់គាត់មាននៅក្នុងបញ្ជីឯកសារចុងក្រោយរបស់ ក.ស.ព ដែលបានដាក់នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤ ជាពិសេស ចម្លើយនេះត្រូវបានកំណត់អត្តសញ្ញាណថាជាចម្លើយទាក់ទងនឹងមន្ទីរសន្តិសុខក្រាំងតាចាន់[73]។ ឯកសារនេះត្រូវបានប្រើប្រាស់ជាច្រើនលើកមកហើយជាមួយនឹងសាក្សីនៅក្នុងតុលាការ ជាពិសេស ជាមួយនឹងអតីត

---

នា ឆ្នាំ ២០១៥ (សួត្រ សាំង)។ ប្រតិចារឹក ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៥ (វ៉ាន់ សឿន)។ ឧបសម្ព័ន្ធ ឃ៖ ប្លង់មន្ទីរសន្តិសុខក្រាំងតាចាន់ដែលត្រូវបានចងក្រងពីព័ត៌មានដែលផ្តល់ឱ្យដោយសាក្សី សយ សែន ឯកសារ D3/5830 ថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ២០១៥។

[71] កំណត់ហេតុសម្ភាត់បំផុតនៃការស្តាប់ចម្លើយសាក្សី [ត្រូវបានកោសលុប] ឯកសារ E319/12.3.6 ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១៤ ទំព័រ ៧, ១០។

[72] កំណត់ហេតុសម្ភាត់បំផុតនៃការស្តាប់ចម្លើយសាក្សី [ត្រូវបានកោសលុប] ឯកសារ E319/12.3.6 ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១៤ ទំព័រ ៦, ៩។

[73] ឧបសម្ព័ន្ធ ១២ ក សម្ងាត់៖ ចម្លើយសាក្សី ឯកសារ E305/13.12 ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤ ទំព័រ ១៦៥។

បុគ្គលិកក្រាំងតាចាន់[74]។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា នួន ជា ខកខានមិនបានបំពេញការយកចិត្តទុកដាក់ឲ្យបានខ្ជាប់ខ្ជួន ហើយសំណើសុំនេះទាក់ទងនឹង សាំង ស៊ីម (2-TCW-1021) ពុំបានធ្វើឡើងទាន់ពេលវេលាកំណត់នោះទេ។

៤៣. ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មេធាវីការពារក្តី នួន ជា បានដឹងអំពី គួច (2-TCW-1022) និង អ៊ួក (2-TCW-1023) នៅមុនពេលចាប់ផ្តើមការជំនុំជម្រះនៅក្នុងឆ្នាំ ២០១១[75] ហើយចម្លើយទាំងឡាយដែលត្រូវបានលើកឡើងអំពីពួកគេក៏មាននៅក្នុងបញ្ជីឯកសារចុងក្រោយរបស់ ក.ស.ព ផងដែរថាមានការជាប់ពាក់ព័ន្ធចំពោះមន្ទីរសន្តិសុខក្រាំងតាចាន់[76]។ ទោះបីជាយ៉ាងនេះក៏ដោយ មេធាវីការពារក្តី នួន ជា ពុំបានស្នើសុំឲ្យបន្ថែមសាក្សីទាំងនេះឡើយ រហូតដល់ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៥[77]។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា មេធាវីការពារក្តី ខកខានមិនបានបំពេញការយកចិត្តទុកដាក់ឲ្យបានខ្ជាប់ខ្ជួន ហើយសំណើសុំទាក់ទងនឹង គួច (2-TCW-1022) និង អ៊ួក (2-TCW-1023) ពុំបានធ្វើឡើងទាន់ពេលវេលាកំណត់នោះដែរ។

---

[74] *សូមមើល* ប្រតិចារឹក ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ (ស្រី ថន)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ (ស្រី ថន)។ ប្រតិចារឹក ថ្ងៃទី ៣ ដល់ ថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១៥ (វ៉ាន់ សឿន)។ ប្រតិចារឹក ថ្ងៃទី ២៤ ដល់ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៥ (សូត្រ សាំង)។

[75] សំណើរួមរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងសុំស្តាប់សាក្សីបន្ថែមសម្រាប់សវនាការផ្នែកទីមួយនៃសំណុំរឿង ០០២/០២ អំពីសហករណ៍ស្រុកត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ ឯកសារ E346 ថ្ងៃទី ៣ ខែ មេសា ឆ្នាំ២០១៥ លេខយោងជើងទំព័រ ៤៣ ដែលយោងលើកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាំង ស៊ីម ឯកសារ D40/20 ថ្ងៃទី២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សូត្រ សាំង ឯកសារ D40/21 ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ២០០៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ សឿន ឯកសារ D40/23 ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្រី ថន ឯកសារ D232/93 ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្រី ថន ឯកសារ D232/93 ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៩។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា កំណត់ហេតុនៃការស្តាប់ចម្លើយដូចបានរៀបរាប់ខាងលើត្រូវបានកំណត់លេខ E3 ដូចតទៅ៖ ឯកសារ D40/23 ពេលនេះគឺជា ឯកសារ E3/5853 ឯកសារ D40/21 ពេលនេះគឺជាឯកសារ E3/5864 ឯកសារ D40/23 ពេលនេះគឺជាឯកសារ E3/5845 និងឯកសារ D232/93 ពេលនេះគឺជាឯកសារ E3/5834។

[76] ឧបសម្ព័ន្ធ ១២ក សម្ងាត់៖ ចម្លើយសាក្សី ឯកសារ E305/13.12 ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤ ទំព័រ ១៦៥, ១៩៩, ២០១, ២៣២។

[77] សំណើសុំ កថាខណ្ឌ ១៧។

៤៤. អង្គជំនុំជម្រះយល់ឃើញទៀតថា មេធាវីការពារក្តី នួន ជា ខកខានមិនបានបង្ហាញថា អង្គជំនុំ-ជម្រះគួរស្តាប់សក្ខីកម្មរបស់ សាំង ស៊ីម (2-TCW-1021), តូច (2-TCW-1022) ឬ អ៊ឹក (2-TCW-1023) ដើម្បីផលប្រយោជន៍នៃយុត្តិធម៌ ឬ សាក្សីទាំងនេះទំនងជាអាចផ្តល់នូវព័ត៌មានដោះបន្ទុកដែលគួរពិនិត្យមើល ដើម្បីជៀសវាងនូវភាពមិនត្រឹមត្រូវក្នុងការស្វែងរកយុត្តិធម៌ឡើយ។ លើសពីនេះ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ទោះក្នុងករណីណាក៏ដោយ បើទោះជាមេធាវីការពារក្តី នួន ជា អះអាងថា ពួកគេអាចបង្ហាញឱ្យមើលឃើញស៊ីជម្រៅអំពីការសម្លាប់កូនក្មេងតូចៗចំនួនពីរនាក់ និងការបំពារបំពានផ្លូវភេទដូចបានចោទប្រកាន់ ដែលត្រូវបានពិភាក្សានៅក្នុងអំឡុងការជំនុំជម្រះលើអង្គហេតុនេះ ព្រមទាំងលក្ខខណ្ឌទូទៅ និងប្រតិបត្តិការនៃមន្ទីរសន្តិសុខក៏ដោយ[78] ក៏អង្គជំនុំជម្រះបានស្តាប់ភស្តុតាងគ្រប់គ្រាន់ទាក់ទងនឹងប្រតិបត្តិការ ការសម្លាប់ អ្នកទោស បុគ្គលិក និងស្ថានភាពមន្ទីរសន្តិសុខក្រាំងតាចាន់រួចហើយ រួមទាំងទស្សនៈរបស់អតីតបុគ្គលិកទាំងនោះផងដែរ[79]។ ទាក់ទងនឹងករណីនេះ អង្គជំនុំជម្រះសូមរំលឹកឡើងវិញថា ការស្វែងរកការពិតពុំចាំបាច់តម្រូវឱ្យស្តាប់សក្ខីកម្មសាក្សីទាំងអស់ដោយមិនមានចំនួនកំណត់នោះទេ[80]។

៤៥. ចំពោះសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី នួន ជា ដែលថា សាក្សីបីរូបដែលបានស្នើសុំកោះហៅអាចបញ្ជាក់បំភ្លឺអំពីការបំពារបំពានផ្លូវភេទទៅលើស្ត្រីដែលបានចោទប្រកាន់ អង្គជំនុំជម្រះសូមគូសបញ្ជាក់សេចក្តីសម្រេចរបស់ខ្លួនកាលពីលើកមុនឡើងវិញថា ទោះបីជាហេតុការណ៍នៃការរំលោភផ្លូវភេទអាចជាប់ពាក់ព័ន្ធនឹងស្ថានភាពនៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ក៏ដោយ ក៏ជនជាប់-ចោទនៅក្នុងសំណុំរឿង ០០២/០២ ពុំត្រូវបានចោទប្រកាន់ពីបទរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនោះទេ[81]។

---

[78] សំណើសុំ កថាខណ្ឌ ១៧។

[79] *សូមមើល* ប្រតិចារឹក ១៩ ថ្ងៃទី ២៣ ដល់ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ (ស្រី ថន)។ ប្រតិចារឹក ថ្ងៃទី ៣ ដល់ ថ្ងៃទី ៥ ខែមីនា ឆ្នាំ ២០១៥ (វ៉ាន់ សឿន)។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយ សាំង ស៊ីម ឯកសារ D40/20 ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧។ ប្រតិចារឹក ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១៥ (កែវ ច័ន្ទតារា)។ ប្រតិចារឹក ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥ (មាស សុមា)។

[80] *សូមមើលដូចខាងលើ* កថាខណ្ឌ 29-32។

[81] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឱ្យមានការតទល់គ្នារវាងដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ជាមួយនឹងសាក្សី ស្រី ថន និងដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង និងស្នើសុំឯកសារថតសម្លេងនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ឯកសារ E348/4 ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០១៥ កថាខណ្ឌ ១១។

៤៦. ជាចុងក្រោយ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា អង្គជំនុំជម្រះមិនបានដឹងថាតើ តួច (2-TCW-1022) និង អ៊ួក (2-TCW-1023) នៅរស់រានមានជីវិតនៅឡើយ ឬ ក៏យ៉ាងណានោះទេ[82]។

៤៧. ដោយផ្អែកលើកាលៈទេសៈទាំងនេះ អង្គជំនុំជម្រះច្រានចោលសំណើរបស់មេធាវីការពារក្តី នួន ជា សុំកោះហៅ សាំង ស៊ីម (2-TCW-1021), តួច (2-TCW-1022) ឬ អ៊ួក (2-TCW-1023)។

**៤.៤ អតីតកម្មាភិបាលស្រុកតាំកក់ សាន់ ឡូន (2-TCW-1007) និង ទឹម ហ៊ី (2-TCW-833)**

៤៨. ជាបឋម អង្គជំនុំជម្រះបានពន្យារពេលក្នុងការចេញសេចក្តីសម្រេចរបស់ខ្លួនទាក់ទងនឹង សាន់ ឡូន (2-TCW-1007) និង ទឹម ហ៊ី (2-TCW-833) ដោយហេតុថា នៅពេលស្នើសុំនោះ អង្គជំនុំជម្រះ កំពុងទន្ទឹងរង់ចាំស្តាប់ភស្តុតាងបន្ថែមពីកម្មាភិបាលតាំក្រក់ (ខឹម ហឿន (2-TCW-979) និង ឯក ហឿន (2-TCW-822) ដែលអង្គជំនុំជម្រះយល់ឃើញថាអាចមានផលប៉ះពាល់លើការវាយតម្លៃ របស់អង្គជំនុំជម្រះលើភាពពាក់ព័ន្ធនៃការស្តាប់សក្ខីកម្មសាក្សីបន្ថែមទាំងនេះ ដែលបានស្នើសុំដោយ មេធាវីការពារក្តី នួន ជា[83]។

៤៩. នៅពេលដំបូង អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សាន់ ឡូន (2-TCW-1007) ត្រូវបាន ក.ស.ច.ស ស្តាប់ចម្លើយនៅក្នុងខែ កញ្ញា ឆ្នាំ ២០១៤ ហើយចម្លើយរបស់គាត់ត្រូវបានដាក់បង្ហាញជូនមេធាវី ការពារក្តីនៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៥[84]។ ដូច្នេះ មេធាវីការពារក្តី នួន ជា ពុំមានចម្លើយរបស់

---

[82] ប្រតិចារឹក ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៥ (សយ សែន) ទំព័រ ៤២, ៤៨។ ប្រតិចារឹក ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៥ (សូត្រ សាំង) ទំព័រ ៣-៥។ យោងតាម សយ សែន, តួច ស្លាប់ហើយ ប្រតិចារឹក ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៥ (សយ សែន) ទំព័រ ៤៨។ បុគ្គលផ្សេងទៀតមិនអាចចងចាំ អ៊ួក បាននោះទេ ប្រតិចារឹក ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ (សៅ ហ៊ាន) ទំព័រ ៥។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ (ស្រី ថន) ទំព័រ ៨។

[83] សេចក្តីសម្រេចលើសំណើសុំរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ទំព័រ ១-២។

[84] ឧបសម្ព័ន្ធ ក សម្ងាត់បំផុត៖ ការដាក់បង្ហាញឯកសារសំណុំរឿង ០០៤ ទាក់ទងនឹងសំណុំរឿង ០០២ ឯកសារ E319/13.3 ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ ទំព័រ ១០។

[85] ប្រតិចារឹក ថ្ងៃទី ២២ ដល់ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ (ពេជ្រ ជឹម)។ ប្រតិចារឹក ថ្ងៃទី ៤ ដល់ ថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១៥ (ខឹម ហឿន)។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ (រ៉ាន់ សឿន) ទំព័រ ១០។

គាត់នៅមុនពេលចាប់ផ្តើមការជំនុំជម្រះនោះទេ ហើយអង្គជំនុំជម្រះជឿជាក់ថា សំណើសុំទាក់ទងនឹងសាក្សីរូបនេះបានធ្វើឡើងទាន់ពេលវេលាកំណត់។

៥០. មេធាវីការពារក្តី នួន ជា សន្និដ្ឋានថា សាន់ ឡួន (2-TCW-1007) អាចផ្តល់សក្ខីកម្មអំពីថ្នាក់ដឹកនាំនៅក្នុងស្រុកត្រាំកក់ទាក់ទងនឹងការបញ្ជូនបញ្ហា ការដឹកមនុស្ស និងព័ត៌មានលម្អិតអំពីតួនាទី *ក្នុងនោះរួមមាន* ពេជ្រ ជឹម (2-TCW-809) និង ខឹម បឿន (2-TCW-979)។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា អង្គជំនុំជម្រះបានស្តាប់លម្អិតអំពីមុខងាររបស់សហករណ៍ត្រាំកក់ និងថ្នាក់ដឹកនាំនៅកន្លែងនោះ រួមទាំងការស្តាប់សក្ខីកម្មដោយផ្ទាល់ពី ពេជ្រ ជឹម (2-TCW-809) និង ខឹម បឿន (2-TCW-979) ផងដែរ[85]។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា សក្ខីកម្មរបស់ សាន់ ឡួន (2-TCW-1007) លើករណីនេះទំនងជាច្រំដែលជាមួយនឹងសក្ខីកម្មរបស់សាក្សីដែលអង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរួចហើយ។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះកត់សម្គាល់ថា ក្រោយពេលអង្គ-ជំនុំជម្រះចេញសេចក្តីសម្រេចរបស់ខ្លួនជាមួយនឹងសំអាងហេតុនឹងចេញតាមក្រោយ ដោយបានពន្យារពេលចេញសេចក្តីសម្រេចលើ សាន់ ឡួន (2-TCW-1007), សាន់ ឡួន ត្រូវបាន ឯក ហឿន (2-TCW-822) ឆ្លើយដាក់ថាបានដឹកជញ្ជូនជនជាតិវៀតណាមទៅទីកន្លែងសម្លាប់មនុស្ស[86]។ អង្គ-ជំនុំជម្រះក៏កត់សម្គាល់ឃើញផងដែរថា សាក្សីមួយរូបទៀតមកពីស្រុកត្រាំកក់បានផ្តល់ភស្តុតាងថា បុគ្គលខ្លះដែលគាត់ជឿថាបានអះអាងថាជាជនជាតិវៀតណាមត្រូវបានគេដឹកតាមឡានទៅតំបន់ភ្នំមួយដែលនៅទីនោះ តាមការចោទប្រកាន់ ពួកគេត្រូវបានគេសម្លាប់ចោល[87]។ ដោយយល់ឃើញថា ដីកាដំណោះស្រាយចោទប្រកាន់ថា ជនជាតិវៀតណាមត្រូវបានគេកំណត់គោលដៅ និងសម្លាប់ចោលនៅទូទាំងប្រទេសកម្ពុជា រួមទាំង ក្នុងខេត្តតាកែវផងដែរនោះ[88] អង្គជំនុំជម្រះយល់

[85] ប្រតិចារឹក ថ្ងៃទី ២២ ដល់ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ (ពេជ្រ ជឹម)។ ប្រតិចារឹក ថ្ងៃទី ៤ ដល់ ថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១៥ (ខឹម បឿន)។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ (វ៉ាន់ សឿន) ទំព័រ ១០។

[86] សេចក្តីសម្រេចលើសំណើសុំរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ទំព័រ ២។ ប្រតិចារឹក ថ្ងៃទី ៧ ខែឧសភា ឆ្នាំ ២០១៥ (ឯក ហឿន) ទំព័រ ៧៦-៧៧, ៨៤-៨៥។ *សូមមើលផងដែរ* ចម្លើយរបស់ សាន់ ឡួន (2-TCW-1007) កំណត់ហេតុនៃការស្តាប់ចម្លើយសម្ងាត់បំផុត [គួសលុបចោល] ឯកសារ E319/13.3.60 ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ទំព័រ ៥៧-៥៨។

[87] ប្រតិចារឹក ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៥ (ជាំង ស្រីមុំ) ទំព័រ ៣៦-៣៧, ៧៩-៨១។

[88] សូមមើល ដីកាដំណោះស្រាយ កថាខណ្ឌ ៨០៣-៨០៤។

ឃើញថា ការស្តាប់សក្ខីកម្ម សាន់ ឡូន (2-TCW-1007) អាចជួយដល់អង្គជំនុំជម្រះក្នុងការបញ្ជាក់ពីការពិតទាក់ទងនឹងការប្រព្រឹត្តិលើជនជាតិវៀតណាមបាន។ ដូច្នេះ អង្គជំនុំជម្រះកោះហៅ សាន់ ឡូន (2-TCW-1007) ឱ្យមកផ្តល់សក្ខីកម្មទាក់ទងនឹងការជំនុំជម្រះលើអង្គហេតុស្តីពីការប្រព្រឹត្តិលើជនជាតិវៀតណាម។

៥១. ទាក់ទងនឹង ទឹម ហ៊ី (2-TCW-933) អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សាក្សីនេះត្រូវបាន ក.ស.ព ស្នើសុំនៅក្នុងបញ្ជីឈ្មោះចុងក្រោយស្តីពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ[89]។ ចម្លើយដំបូងរបស់គាត់ ចុះកាលបរិច្ឆេទថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៨ ដែលនៅក្នុងនោះគាត់លើកឡើងថា គាត់គឺជានីរសាររបស់ តា ជឹម នៅក្នុងឆ្នាំ ១៩៧៧ និងរៀបរាប់អំពីហេតុការណ៍នៃការធ្វើទារុណកម្ម។ សំណៅដើមជាភាសាខ្មែរនៃចម្លើយនេះត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងនៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៩ ហើយសំណៅបកប្រែជាភាសាអង់គ្លេសត្រូវបានដាក់ នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១២[90]។ ម្យ៉ាងវិញទៀត ចម្លើយបន្ថែមដែល ទឹម ហ៊ី (2-TCW-933) បានផ្តល់ជូន ក.ស.ច.ស ត្រូវបានដាក់បង្ហាញជូនមេធាវីការពារក្តី នួន ជា នៅថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤។ ទោះបីជាយ៉ាងនេះក៏ដោយ មេធាវីការពារក្តី នួន ជា ពុំបានស្នើសុំស្តាប់សក្ខីកម្មសាក្សីរូបនេះទេរហូតដល់ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៥ នៅពេលដែលអង្គជំនុំជម្រះរៀបនឹងឈានដល់ការបញ្ចប់លើអង្គហេតុនេះរួចទៅហើយ[91]។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា មេធាវីការពារក្តី នួន ជា ខកខានមិនបានបំពេញការយកចិត្តទុកដាក់ឱ្យបានខ្ជាប់ខ្ជួន ហើយសំណើសុំទាក់ទងនឹង ទឹម ហ៊ី (2-TCW-933) ពុំបានដាក់ទាន់ពេលវេលាកំណត់នោះទេ។ អង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា មេធាវីការពារក្តី នួន ជា ខកខានមិនបានផ្តល់ហេតុផលគួរឱ្យជឿជាក់ថាហេតុអ្វីអង្គជំនុំ-

---

[89] ឧបសម្ព័ន្ធ I សម្ងាត់៖ បញ្ជីរួមដែលបានកែសម្រួលរួចហើយរបស់សហព្រះរាជអាជ្ញាស្តីពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសម្រាប់សំណុំរឿង ០០២/០២ ទៅតាមលំដាប់លំដោយនៃវគ្គជំនុំជម្រះ និងការបង្ហាញខ្លួនដូចដែលបានស្នើឡើង (ខែកក្កដា ឆ្នាំ ២០១៤) ឯកសារ E307/3/2.2 ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៤។

[90] ពាក្យបណ្តឹងសម្ងាត់របស់ ទឹម ហ៊ី ឯកសារ D230/1.1.607a ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៨។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ១៣ក សម្ងាត់៖ ពាក្យបណ្តឹង ឯកសារ D305/13.13 ទំព័រ ៤៤។

[91] សេចក្តីជូនដំណឹងអំពីការទទួលយករបស់ នួន ជា ចំពោះឯកសារដែលបានដាក់បង្ហាញពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនៃសហករណ៍ទានានៅត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ ឯកសារ E319/4 ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៤។

ជម្រះគួរស្ដាប់សក្ខីកម្មរបស់សាក្សីរូបនេះដើម្បីផលប្រយោជន៍នៃយុត្តិធម៌ ហើយក៏មិនបានលើកឡើងថា សាក្សីរូបនេះអាចផ្ដល់ព័ត៌មានដោះបន្ទុកនោះដែរ។

៥២. ទោះបីជាយ៉ាងនេះក៏ដោយ អង្គជំនុំជម្រះយល់ឃើញថា ភ័ស្តុតាងរបស់ ទឹម ហុី (2-TCW-933) អាចជាប់ពាក់ព័ន្ធនឹងអង្គហេតុនៃការបោសសម្អាតផ្ទៃក្នុង។ អង្គជំនុំជម្រះក៏កត់សម្គាល់ផងដែរថា ភាគីផ្សេងទៀតពុំបានជំទាស់ចំពោះការកោះហៅសាក្សីរូបនេះឡើយ[92]។ ដូច្នេះ អង្គជំនុំជម្រះនឹងពិចារណាលើ ទឹម ហុី (2-TCW-933) នៅពេលជ្រើសរើសសាក្សីសម្រាប់ការជំនុំជម្រះលើអង្គហេតុនៃការបោសសម្អាតផ្ទៃក្នុង។

## <u>៤.៥. សាក្សីអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ - សេង អុល (2-TCW-1025) និង ទ្រី ទូច (2-TCW-1024)</u>

៥៣. អង្គជំនុំជម្រះបានពន្យារពេលចេញសេចក្ដីសម្រេចលើសំណើសុំទាក់ទងនឹង សេង អុល (2-TCW-1025) និង ទ្រី ទូច (2-TCW-1024) ដោយហេតុថា អង្គជំនុំជម្រះយល់ឃើញថា សំណើសុំនេះបានធ្វើឡើងមុនដំណាក់កាលនីតិវិធី ក្រោយពីពិនិត្យមើលអង្គហេតុចំបងដែលនឹងរៀបរាប់ដោយសាក្សីទាំងនេះ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា អង្គហេតុនៃការជំនុំជម្រះទាំងមូលគឺផ្ដោតលើអង្គហេតុនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយអង្គជំនុំជម្រះពុំទាន់បានធ្វើការជ្រើសរើសក្នុងចំណោមសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើឡើងដោយភាគីទាំងអស់នៅឡើយទេ។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា វាជាការសមស្របក្នុងការពិចារណាសំណើសុំនេះ នៅពេលអង្គជំនុំជម្រះធ្វើការជ្រើសរើសបែបនោះ។

៥៤. ទោះបីជាយ៉ាងនេះក៏ដោយ ជាបញ្ហាបឋម អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មេធាវីការពារក្ដី នួន ជា មានចម្លើយរបស់ សេង អុល (2-TCW-1025) នៅមុនពេលចាប់ផ្ដើមការជំនុំជម្រះនៅក្នុងឆ្នាំ ២០១១[93]។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា មេធាវីការពារក្ដី នួន ជា ខកខានមិនបានបំពេញការយកចិត្តទុកដាក់ឲ្យបានខ្ជាប់ខ្ជួន ហើយសំណើសុំនេះពុំបានធ្វើឡើងទាន់ពេលវេលា

---

[92] *សូមមើលដូចខាងលើ* កថាខណ្ឌ ២០ និង ២៦ ។ សហមេធាវីនាំមុខគ្រាន់តែស្នើសុំឲ្យអង្គជំនុំជម្រះពិចារណាលើសេចក្ដីសន្និដ្ឋានបឋមរបស់ខ្លួននៅពេលសម្រេចលើសាក្សីរូបនេះ *សូមមើលដូច "ចម្លើយតបរបស់សហមេធាវីនាំមុខ"* កថាខណ្ឌ ១១-១៥,២៣។

[93] សំណើសុំ កថាខណ្ឌ ២៣។

កំណត់នោះទេ។ ដូច្នេះ អង្គជំនុំជម្រះនឹងជ្រើសរើសសាក្សីរូបនេះ ប្រសិនបើអង្គជំនុំជម្រះជឿជាក់ថា ផលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យអង្គជំនុំជម្រះស្តាប់សក្ខីកម្មរបស់គាត់ ជាពិសេស ប្រសិនបើវាទាក់ទងនឹងព័ត៌មានដោះបន្ទុក និងតម្រូវឱ្យពិនិត្យមើលសាក្សីរូបនេះដើម្បីជៀសវាងភាពមិនត្រឹមត្រូវក្នុងការស្វែងរកយុត្តិធម៌[94]។

## ៤.៦. សំណើសុំលើយថភាពនៃឯកសារ - ស៊ូ ភីរិន្ទ (2-TCW-1027) និង អ៊ីវ សារិ (2-TCW-1026)

៥៥. មេធាវីការពារក្តី នួន ជា ទទួលស្គាល់ថា សំណើសុំស្តាប់ ស៊ូ ភីរិន្ទ (2-TCW-1027) និង អ៊ីវ សារិ (2-TCW-1026) គួរតែធ្វើឡើង នៅមុនចាប់ផ្តើមការជំនុំជម្រះ[95]។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា យ៉ាងហោចណាស់ មេធាវីការពារក្តី នួន ជា មានព័ត៌មានទាក់ទងនឹងសាក្សីសក្តានុពលទាំងពីររូបនេះតាំងពីឆ្នាំ ២០០៩ មកម្លេះ[96] ហើយថា នៅក្នុងខែ ធ្នូ ឆ្នាំ ២០០៩ មេធាវីការពារក្តីបានធ្វើសំណើសុំបំពេញកិច្ចស៊ើបសួរ ទៅសហចៅក្រមស៊ើបអង្កេតដើម្បីបង្ហាញនូវខ្សែសង្វាក់នៃការរក្សាទុកឯកសារជាច្រើន រួមទាំង ឯកសារក្រាំងតាចាន់ដែលកំពុងចោទជាបញ្ហាផងដែរ[97]។ នៅក្នុងដីកាសម្រេចបដិសេធសំណើសុំនេះ សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា ពួកគេបាន "ស៊ើប-អង្កេតលើប្រព័ន្ធនៃការរក្សាទុកភស្តុតាងលើឯកសារមួយចំនួន"[98]។ បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតត្រូវបានអង្គបុរេជំនុំជម្រះ

---

[94] *សូមមើលដូចខាងលើ* កថាខណ្ឌ ៣១។

[95] សំណើសុំ កថាខណ្ឌ ២៦។

[96] សំណើសុំលើកទី១៧ សុំឱ្យបំពេញកិច្ចស៊ើបសួរ ឯកសារ D265 ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៩ [សម្ងាត់] កថាខណ្ឌ ៤ យោងលើផ្នែកនៃកំណត់ហេតុនៃការស្តាប់ចម្លើយ ឆាំង យុ (2-TCW-870) ដែល ស៊ូ ភីរិន្ទ និង អ៊ីវ សារិ ត្រូវបានលើកឡើងទាក់ទងនឹងឯកសារក្រាំងតាចាន់។

[97] សំណើសុំលើកទី១៧ សុំឱ្យបំពេញកិច្ចស៊ើបសួរ ឯកសារ D265 ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៩ [សម្ងាត់] កថាខណ្ឌ ១-២, ៤, ១៨។

[98] ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១៦ (D253) និង១៧ (D265) របស់ នួន ជា ឯកសារ D265/2 ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១០ [សម្ងាត់] កថាខណ្ឌ ៩។ *សូមមើលផងដែរ*បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស លើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១៦ (D253) និង១៧ (D265) របស់ នួន ជា ឯកសារ D253/3/1 ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១០ [សម្ងាត់]។ សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១៦ (D253) និង១៧ (D265) ឯកសារ D253/3/5 ថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០១០។

រកឃើញថាមិនអាចទទួលយកបាន[99]។ អង្គបុរេជំនុំជម្រះមិនជឿជាក់ថា សំណើរបស់មេធាវីការពារក្តី នួន ជា សុំបំពេញកិច្ចស៊ើបសួរមានគោលបំណងក្នុងការប្រមូលព័ត៌មានដែលស្វែងរកការពិត ហើយអង្គបុរេជំនុំជម្រះបានរំលឹកដល់មេធាវីការពារក្តី នួន ជា ថា ពួកគេនៅមានឱកាសជំទាស់លើយថាភាពនៃឯកសារ ដែលសំអាងដោយសហចៅក្រមស៊ើបអង្កេតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបាន[100]។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា សំណើសុំរបស់ នួន ជា ទាក់ទងនឹងសាក្សីទាំងពីររូបនេះ មិនបានធ្វើឡើងទាន់ពេលវេលាកំណត់នោះទេ។ នាពេលនេះ អង្គជំនុំជម្រះនឹងពិចារណាថាតើវាជាផលប្រយោជន៍នៃយុត្តិធម៌ដែរ ឬ ទេក្នុងការកោះហៅសាក្សីទាំងនេះ[101]។

៥៦. មេធាវីការពារក្តី នួន ជា សន្និដ្ឋានថា វាមានសារៈសំខាន់ក្នុងការស្តាប់សាក្សីទាំងនេះនាពេលនេះ ដោយសារតែមានការសំអាងយ៉ាងច្រើនសន្ធឹកសន្ធាប់លើឯកសារទាំងនេះនៅក្នុងអំឡុងនៃការជំនុំជម្រះអង្គហេតុទីមួយ[102]។ ទាក់ទងនឹងករណីនេះ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ដីកាដំណោះស្រាយសំអាងលើឯកសារមួយចំនួន ក្នុងចំណោមឯកសារក្រាំងតាចាន់ដែលត្រូវបានជំទាស់ ហើយថា មេធាវីការពារក្តីត្រូវបានជូនដំណឹងថា សហព្រះរាជអាជ្ញាមានបំណងសំអាងលើឯកសារទាំងនេះនៅក្នុងសំណុំរឿង ០០២/០២ យ៉ាងហោចណាស់តាំងតែពីខែ មិថុនា ឆ្នាំ ២០០៤ មកម្លេះ នៅពេលសហព្រះរាជអាជ្ញាបានដាក់បញ្ជីឯកសារចុងក្រោយរបស់ពួកគេ និងសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់នៅក្នុងខែ តុលា ឆ្នាំ ២០១៤[103]។

---

99 សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១៦ (D253) និង១៧ (D265) ឯកសារ D253/3/5 ថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០១០ កថាខណ្ឌ ១២។

100 សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១៦ (D253) និង១៧ (D265) ឯកសារ D253/3/5 ថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០១០ កថាខណ្ឌ ១១, ១៣។

101 *សូមមើលដូចខាងលើ* កថាខណ្ឌ ៣១។

102 សំណើសុំ កថាខណ្ឌ ២៦។

103 ដីកាដំណោះស្រាយ កថាខណ្ឌ ៤៩០-៥១៣។ ឧបសម្ព័ន្ធ ៨ក សម្ងាត់៖ កំណត់ហេតុស្រុកត្រាំកក់ ឯកសារ E305/13.8 ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤។ ប្រតិចារឹក ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ១៩-២០។ នៅក្នុងអំឡុងពេលធ្វើសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់ សហព្រះរាជអាជ្ញាបានលើកឡើងថា "ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្រាំងតាចាន់នឹងត្រូវបានបង្ហាញ

៥៧. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ឯកសារក្រាំងតាចាន់ដែលត្រូវបានជំទាស់នេះគឺសំណៅថតចម្លង ហើយអង្គជំនុំជម្រះសូមរំលឹកថា ទោះបីជាសំណៅដើមគឺជាប្រភេទភស្តុតាងដែលចង់បានជាង ហើយអាចមានទម្ងន់ជាងសំណៅថតចម្លងក៏ដោយ ក៏សំណៅថតចម្លងអាចដាក់នៅចំពោះមុខ អ.វ.ត.ក បានដែរ[104]។

៥៨. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ឯកសារក្រាំងតាចាន់ភាគច្រើនត្រូវបានរកឃើញថាមានលក្ខណៈពាក់ព័ន្ធ និងអាចជឿជាក់បាន*ជាបឋម* រួមទាំង មានយថាភាពផងដែរ ហើយមានលក្ខណៈស៊ីសង្វាក់ជាមួយនឹងភស្តុតាងផ្សេងទៀត នៅចំពោះមុខអង្គជំនុំជម្រះនេះ រួមទាំង សក្ខីកម្មរបស់សាក្សីមួយចំនួនដែលអង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរួចហើយផងដែរ[105]។ ការសម្រេចនេះបានពិចារណាលើករណីដែលថា ឯកសារមួយចំនួនត្រូវបានសំអាងនៅក្នុងដីកាដំណោះស្រាយ ខណៈ

---

*ពុំមែនតាមរយៈកំណត់ហេតុក្រាំងតាចាន់រាបរយដែលនៅសេសសល់នោះទេ*ប៉ុន្តែក៏ដោយតាមរយៈសក្ខីកម្មរបស់អ្នកជាប់ឃុំឃាំងដែលនៅរស់រានមានជីវិតផងដែរ [...]" ប្រតិចារឹក ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ២០ (ការគូសបញ្ជាក់បន្ថែម)។

[104] *សូមមើល* សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១ ឯកសារ E185 ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ២១។

[105] ឯកសារក្រាំងតាចាន់ចំនួន ១៣៦ ត្រូវបានទទួលយកមកដាក់បញ្ចូលនៅក្នុងភស្តុតាង សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 របស់សហព្រះរាជអាជ្ញា និងឯកសារដែលបានស្នើឡើងដោយភាគីផ្សេងទៀត ឯកសារ E185/1 ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ៩-១៣។ ឧបសម្ព័ន្ធ គ - សេចក្តីសម្រេចលើកទីបីលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំឱ្យទទួលយកនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E185/2 ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ២៧។ ឧបសម្ព័ន្ធ ខ - ឯកសារដែលបានស្នើសុំឱ្យទទួលយកនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដោយការិយាល័យសហព្រះរាជអាជ្ញា ការជម្លៀសប្រជាជនដំណាក់កាលទី I ឯកសារ E185/2.2 ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៣។ សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារទាំងឡាយដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ឯកសារ E305/17 ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥។ *សូមមើល* ឧបសម្ព័ន្ធ ក៖ ឯកសារទាំងឡាយដែលបានស្នើដាក់ដោយសហព្រះរាជអាជ្ញានៅចំពោះមុខអង្គជំនុំជម្រះ ឯកសារ E305/17.1 ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥។ ជាពិសេស*សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ២១ ដល់ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ (មាស សុខា)។ ប្រតិចារឹក ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១៥ (កែវ ច័ន្ទតារា)។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ (ស្រី ថន)។ ប្រតិចារឹក ថ្ងៃទី ៤ ដល់ ថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១៥ (វ៉ាន់ សឿន)។ ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ (ថាន់ ធីម)។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ (ពេជ្រ ជីម)។

ឯកសារផ្សេងទៀតចេញមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាដែលអាចឱ្យគេសន្មតបានថា ឯកសារទាំងនេះមានភាពពាក់ព័ន្ធ និងអាចជឿជាក់បាន ប៉ុន្តែបើកឱ្យជំទាស់តវ៉ាបាន រួមទាំង លើបញ្ហាយថាភាពផងដែរ[106]។ សំណើសុំរបស់ នួន ជា មិនបានជាប់ពាក់ព័ន្ធជាមួយនឹងការជំទាស់តវ៉ាលើយថាភាពយ៉ាងច្បាស់លាស់ចំពោះឯកសារជាក់លាក់នៅក្នុងសំណើសុំនោះទេ[107]។ ជាការពិតណាស់ មេធាវីការពារក្តី នួន ជា បានសំអាងលើឯកសារទាំងនេះមួយចំនួនដើម្បីបង្ហាញថា រូបភាពផ្សេងមួយពីរូបភាពដែលបានឆ្លុះបញ្ចាំងដោយសហព្រះរាជអាជ្ញា អាចបង្ហាញយ៉ាងហោចណាស់លើហេតុការណ៍ខ្លះៗដែលបានស្តែងឱ្យឃើញនៅក្រាំងតាចាន់[108]។ ដូច្នេះ ការជំទាស់តវ៉ាជាក់លាក់ និងមូលដ្ឋានជាក់ស្តែងណាមួយទៅនឹងឯកសារដែលបានកំណត់អត្តសញ្ញាណទាំងនោះនឹងត្រូវអង្គ-ជំនុំជម្រះយកមកដោះស្រាយទៅតាមករណីនីមួយៗ។

៥៩. អង្គជំនុំជម្រះសូមរំលឹកឡើងវិញថា វាពុំមានលក្ខខណ្ឌតម្រូវផ្នែកនីតិវិធីណាមួយ នៅចំពោះមុខ អ.វ.ត.ក ដែលតម្រូវឱ្យកោះហៅសាក្សីដែលបានដឹងឮផ្ទាល់ដើម្បីមកបញ្ជាក់យថាភាពនៃឯកសារនៅក្នុងសំណុំរឿងនោះទេ[109]។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះក៏សូមរំលឹកឡើងវិញផងដែរថា

---

[106] *សូមមើល*សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 របស់សហព្រះរាជអាជ្ញា និងឯកសារដែលបានស្នើឡើងដោយភាគីផ្សេងទៀត ឯកសារ E185/1 ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ៩។ ឧបសម្ព័ន្ធ គ៖ ឯកសារដែលបានស្នើដាក់ដោយសហព្រះរាជអាជ្ញា ឯកសារ E185/1.3 ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២។ ឧបសម្ព័ន្ធ គ - សេចក្តីសម្រេចលើកទីបីលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំឱ្យទទួលយកនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E185/2 ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ២០។

[107] សំណើសុំ កថាខណ្ឌ ២៥-២៨។

[108] ប្រតិចារឹក ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៥ ទំព័រ ៧-២៦។

[109] សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១ ឯកសារ E185 ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ២១.៧។

សក្ខីកម្មទាក់ទងនឹងខ្សែសង្វាក់នៃការរក្សាទុកឯកសារ និងប្រភពឯកសារអាចជួយដល់អង្គជំនុំជម្រះក្នុងការវាយតម្លៃលើទម្ងន់នៃភស្តុតាងដែលត្រូវផ្តល់លើឯកសារជាក់លាក់ទាំងនោះ[110]។

៦០. នៅក្នុងករណីនេះ ព័ត៌មានបន្ថែមពីសំណុំរឿងអំពីខ្សែសង្វាក់នៃការរក្សាទុកឯកសារទាំងអស់ លើកលែងតែឯកសារចំនួនពីរក្នុងចំណោមឯកសារក្រាំងតាចាន់ទាំង ១៣៥ ដែលត្រូវបានជំទាស់នោះ បង្ហាញថា នៅក្នុងខែ ធ្នូ ឆ្នាំ ២០០៩ សហចៅក្រមស៊ើបអង្កេតបានចាត់វិធានការស្វែងរកសំណៅដើមទាំងអស់នោះ[111]។ សហចៅក្រមស៊ើបអង្កេតបានសាកសួរ Ben Kiernan ឲ្យផ្តល់ព័ត៌មានទាក់ទងនឹងសម្ភារៈភស្តុតាង រួមទាំងឯកសារក្រាំងតាចាន់ផងដែរ។ ឯកសារភ្ជាប់រួមជាមួយនឹងសំណើសុំនោះ និងចម្លើយតបរបស់លោក Kiernan មាននៅក្នុងសំណុំរឿង[112]។ នៅក្នុងចម្លើយតប ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១០ លោក Kiernan ពន្យល់ថា នៅក្នុងខែ កក្កដា ឆ្នាំ ១៩៨០ គាត់រួមជាមួយនឹង សុខ សុគន្ធ មកពីក្រសួងព័ត៌មាន និងវប្បធម៌កម្ពុជាបានប្រមូលសំណៅដើមពីមន្ត្រីនៅត្រាំកក់។ ក្រោយពេលធ្វើការថតចម្លងនៅទីក្រុងភ្នំពេញរួចហើយ លោក Kiernan បានប្រគល់សំណៅដើមទាំងនោះឲ្យទៅលោក សុខ សុគន្ធ វិញ ដែលគាត់បានធានាចំពោះលោក

---

[110] *សូមមើល* សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១ ឯកសារ E185 ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ២១.៧។

[111] ឧបសម្ព័ន្ធ ៨ក សម្ងាត់៖ កំណត់ហេតុស្រុកត្រាំកក់ ឯកសារ E305/13.8 ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤។ ចម្លើយតបសម្ងាត់របស់ Ben Kiernan ជូន ស.ច.ស ថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១០ ឯកសារ D269/4 កថាខណ្ឌ ៩។ លិខិតសម្ងាត់របស់ ស.ច.ស ផ្ញើជូន Ben KIERNAN ឯកសារ D269 ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩។ បញ្ជីសម្ងាត់ស្តីពីឧបសម្ព័ន្ធ ឯកសារ D269.1 ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩ ឧបសម្ព័ន្ធ ខ។ ឧបសម្ព័ន្ធ ៨ក សម្ងាត់៖ កំណត់ហេតុស្រុកត្រាំកក់ ឯកសារ E305/13.8 ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤។ ឯកសារចំនួនពីរនៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញាស្តីពីកំណត់ហេតុស្រុកត្រាំកក់ ឯកសារ E3/4164 និង E4166 ពុំឃើញមាននៅក្នុងបញ្ជីឯកសារដែលបានផ្តល់ជូនលោក Kiernan ហើយគាត់អះអាងថាពុំបានដឹងអំពីឯកសារក្រាំងតាចាន់ផ្សេងទៀតឡើយ ចម្លើយតបសម្ងាត់របស់ Ben Kiernan ជូន ស.ច.ស ថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១០ ឯកសារ D269/4 កថាខណ្ឌ ៩។

[112] លិខិតសម្ងាត់របស់ ស.ច.ស ផ្ញើជូន Ben KIERNAN ឯកសារ D269 ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩។ បញ្ជីសម្ងាត់ស្តីពីឧបសម្ព័ន្ធ ឯកសារ D269.1 ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩ ឧបសម្ព័ន្ធ ខ។ ចម្លើយតបសម្ងាត់របស់ Ben Kiernan ជូន ស.ច.ស ថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១០ ឯកសារ D269/4 កថាខណ្ឌ ៩។ *សូមមើលផងដែរ*ឧបសម្ព័ន្ធ ៨ក សម្ងាត់៖ កំណត់ហេតុស្រុកត្រាំកក់ ឯកសារ E305/13.8 ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤។

Kiernan ថា ក្រសួងព័ត៌មាន និងវប្បធម៌នឹងប្រគល់ឯកសារទាំងនោះទៅស្រុកត្រាំកក់វិញ។ លោក Kiernan ពុំបានដឹងថា ឯកសារទាំងនោះពុំដែលបានប្រគល់ត្រឡប់ទៅឱ្យស្រុកត្រាំកក់វិញនោះទេ[113]។ យោងតាមព័ត៌មានដែលលោក Kiernan បានផ្តល់ឱ្យនៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានទាក់ទងទៅ ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន ស្នើសុំព័ត៌មាននានា ក្នុងនោះ ទាក់ទងនឹងទីតាំងឯកសារក្រាំងតាចាន់[114]។ ខៀវ កាញារីទ្ធ បានឆ្លើយតបនៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១០ ថា ក្រសួងព័ត៌មានពុំមាន "ឯកសារក្រាំងតាចាន់" នោះឡើយ[115]។

៦១. អង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា យោងតាម ឆាំង យុ (2-TCW-870), ស៊ូ ភីរិន្ទ (2-TCW-1027) គឺជាមន្ត្រីនៅត្រាំកក់ដែលមានសំណៅដើម មុនពេលដែលឯកសារទាំងនេះបានផ្តល់ឱ្យលោក Kiernan នៅក្នុងខែ កក្កដា ឆ្នាំ ១៩៨០។ ចម្លើយរបស់ ឆាំង យុ (2-TCW-870) ត្រូវបានកត់ត្រាទុកបន្ថែមទៀតដោយគាត់បានឆ្លើយថា ស៊ូ ភីរិន្ទ (2-TCW-1027) បានប្រាប់គាត់ថា សំណៅដើមទាំងនោះបានបាត់អស់ហើយ[116]។ ចំពោះ អ៊ីវ សារិ (2-TCW-1026) អង្គជំនុំជម្រះកត់សម្គាល់ឃើញទៀតថា ទោះបីជាមានការចង្អុលបង្ហាញថា គាត់គឺជាបុគ្គលដែលបានប្រគល់សំណៅដើមផ្ទាល់ទៅឱ្យលោក Kiernan ក៏ដោយ[117] ក៏គ្មានការចង្អុលបង្ហាញណាមួយថា គាត់បានទទួលសំណៅច្បាប់ដើមត្រឡប់មកវិញ ក្រោយពេលលោក Kiernan បានធ្វើការថតចម្លងរួចហើយនោះដែរ។

៦២. អង្គជំនុំជម្រះយល់ឃើញថា សំណុំឯកសារដែលមាននៅក្នុងសំណុំរឿងដូចបានលើកឡើងខាងលើចង្អុលបង្ហាញយ៉ាងស៊ីសង្វាក់គ្នាថា គេពុំបានដឹងអំពីទីតាំងសំណៅដើមទាំងនេះឡើយ ឬ ឯកសារទាំងនេះបានបាត់អស់ទៅហើយ។ ដូច្នេះ អង្គជំនុំជម្រះក៏ពុំជឿជាក់នោះទេថា សក្ខីកម្មរបស់ ស៊ូ ភីរិន្ទ (2-TCW-1027) និង អ៊ីវ សារិ (2-TCW-1026) មានលក្ខណៈសមស្របក្នុងការបញ្ជាក់លើអង្គហេតុទាំងឡាយដូចបានអះអាង ហើយអង្គជំនុំជម្រះយល់ឃើញថា ការធ្វើការស៊ើបសួរបន្ថែមណា

---

[113] ចម្លើយតបសម្ងាត់របស់ Ben Kiernan ជូន ស.ច.ស ថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១០ ឯកសារ D269/4 កថាខណ្ឌ ៩។

[114] សំណើសម្ងាត់សុំព័ត៌មានអំពីឯកសារមួយចំនួន ឯកសារ D268/6 ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១០ ទំព័រ ៣។

[115] ចម្លើយតបសម្ងាត់ពី ខៀវ កាញារីទ្ធ ផ្ញើជូនសហចៅក្រមស៊ើបអង្កេត ឯកសារ D269/6/1 ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១០។

[116] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆាំង យុ ឯកសារ E3/188 ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៤។

[117] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆាំង យុ ឯកសារ E3/188 ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រ ៤។

មួយនៅក្នុងដំណាក់កាលនេះដើម្បីស្វែងរកទីតាំងឯកសារដើមទាំងនេះ នឹងនាំឲ្យមានពន្យារពេលនៃកិច្ចដំណើរការនីតិវិធីពុំសមហេតុផលឡើយ។

៦៣. ទោះក្នុងករណីណាក៏ដោយ អង្គជំនុំជម្រះក៏យល់ឃើញថា ទោះបីជាគេពុំបានដឹងពីទីតាំងនៃឯកសារដើមទាំងនេះក៏ដោយ ក៏សំណុំឯកសារនៅក្នុងសំណុំរឿងបង្ហាញថា ខ្សែសង្វាក់នៃការរក្សាទុកឯកសារមានការកត់ត្រាទុកត្រឹមត្រូវ ឃើញមានតាំងពីខែ កក្កដា ឆ្នាំ ១៩៨០ មកម្លេះ។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា មិនមានភាពចាំបាច់ក្នុងការស្ដាប់សក្ខីកម្មសាក្សីបន្ថែមអំពីខ្សែសង្វាក់នៃការរក្សាទុកឯកសារក្រាំងតាចាន់នោះឡើយ។

៦៤. ហេតុដូច្នេះ អង្គជំនុំជម្រះច្រានចោលសំណើសុំទាក់ទងនឹងការកោះហៅសាក្សីទាំងពីររូបនេះ។

## ៥. <u>សេចក្ដីសម្រេច</u>

**យោងតាមសំអាងហេតុដូចបានបង្ហាញខាងលើ អង្គជំនុំជម្រះសាលាដំបូងសម្រេច៖**

**ច្រានចោល** សំណើសុំកោះហៅសាក្សី មាស សារ៉ាត់ (2-TCW-821), ហ៊ុន គីមសេង (2-TCW-1018) អ៊ូច ហាន (2-TCW-1019), សែត យ៉ែម (2-TCCP-1020), សាំង ស៊ីម (2-TCW-1021), តូច (2-TCW-1022), អ៊ួក (2-TCW-1023), ស៊ូ ភីរិន្ទ (2-TCW-1027) និង អ៊ីវ សារិ (2-TCW-1026)។

**យល់ព្រម** តាមសំណើសុំកោះហៅ វង្ស សារុន (2-TCW-986)។

**យល់ព្រម** តាមសំណើសុំកោះហៅ សៅ វ៉ែន (2-TCW-989) និង សាន់ ឡូន (2-TCW-1007) ប៉ុន្តែលើកពេលស្ដាប់សក្ខីកម្មសាក្សីទាំងនេះ រហូតដល់ការជំនុំជម្រះលើអង្គហេតុដែលផ្ដោតសំខាន់លើការប្រព្រឹត្តិលើមនុស្សជាក្រុមគោលដៅជាក់លាក់។

**ពន្យារពេល** សម្រេចសេចក្តីលើសាក្សីដូចខាងក្រោមរហូតដល់អង្គហេតុដែលត្រូវជំនុំជម្រះនាពេលខាងមុខ ៖ ទឹម ហ៊ី (2-TCW-833), សេង អុល (2-TCW-1025) និង ទ្រី ទូច (2-TCW-1024)។

**រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦**

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE DE PREMIÈRE INSTANCE

**និល ណុន**